**BMI0027**

## សម្ភាសន៍ជាមួយ មៀច ឆាយ ភេទប្រុស អាយុ៥៧ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ មេបញ្ជាការកងពិសេស, កងពល១២
## រស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០
## សម្ភាសដោយ សោម ប៊ុនថន
## ០១:៤៣:១៨
## ២៦ទំព័រ

ឆាយ : ខ្ញុំរៀនដល់ថ្នាក់ទី៦ អនុវិទ្យាល័យ ឆ្នាំ១៩៦៩ ។ ខ្ញុំចង់រៀនតទៅទៀត ស្រាប់តែឮពាក្យមួយ ប្រទេសជាតិយើងខ្លាចមានបញ្ហាអី ។ យើងអត់ដឹងថាមានរឿងអ៊ីទេ ចុងខែ ជិតដាច់ឆ្នាំខ្ញុំក៏ឈប់រៀន ។ ដល់ឆ្នាំ១៩៧០ ក៏មានរដ្ឋប្រហារ ខ្ញុំក៏មិនដឹងធ្វើម៉េច ។ រដ្ឋប្រហារបាន ៣ខែ យួនយៀកកុងវាយឡើងមកដល់ផ្ទះខ្ញុំ គេក៏ឲ្យខ្ញុំចូលបំរើកងទ័ពជាមួយគេ គេអូសខ្ញុំទៅមិនដឹងធ្វើម៉េច ។ ចេះតែតាមគេទៅ គេអូសដល់ណាក៏ខ្ញុំមិនដឹងដែរ ព្រោះខ្ញុំនៅស្ទើរដែរ ។ ប៉ុន្តែខ្ញុំដឹងដែរព្រោះខ្ញុំរៀនដល់ថ្នាក់ហ្នឹងហើយ ។ ខេត្តកណ្តាលហ្នឹងគេដាក់តំបន់៦២ ក្រោយយួនចូលមក គេដាក់ខេត្តអាងយ៉ាង ។ ដល់ពេលយើងរត់ចេញពីយួនអស់មកធ្វើចលនាតស៊ូម្ខាងវាយទៅយួនខាងនេះ ម្ខាងទប់ឆ្នាំ១៩៧០ យើងនៅកណ្តាល អញ្ចឹងយើងបង្កើតតំបន់នេះទៅ២៥វិញ ។ តំបន់នេះ មានស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ ស្រុកលើកដែក ។ កាលពីមុននេះ ស្រុកកៀនស្វាយនៅលើ យើងមិនទាន់បញ្ចូល ប៉ុន្តែមកដល់បច្ចុប្បន្នឥឡូវក៏នៅដដែលដែរ ។ ប៉ុនកាលយើងនៅ ស្រុកកៀនស្វាយមិនទាន់រំដោះទេ យើងដាក់តែស្រុកស្អាង ស្រុកកោះធំ និងស្រុកលើកដែក ទាំងបីស្រុកហ្នឹងតំបន់២៥ ។ ខ្ញុំនៅតស៊ូនៅហ្នឹងរហូត ។ ស្រាប់យើងឯករាជ្យ ១៧ មេសា ឆ្នាំ១៩៧៥ យើងចូលដល់ឆ្នាំពេញ ប៉ុន្តែមិនដឹងគោលការណ៍ខាងលើម៉េច យើងច្របូលច្របល់ យើងកងទ័ពអត់ដឹងទេ ចោះយើងដឹកនាំកងទ័ពដែរ ។ យើងមេបញ្ជាការកងពិសេសប្រចាំកងពល ។

ប៊ុនថន : កងពលលេខប៉ុន្មាន?

ឆាយ : កងពល១២ ។ ខ្ញុំភ្លេចឈ្មោះមេ ។ គាត់គ្រាន់តែបំពាក់ឲ្យយើងហើយ គាត់ផ្លាស់ទៅបាត់ ។

ប៊ុនថន : ដូរថ្មីមក?

ឆាយ ៖ បាទ ហើយខ្ញុំកាលហ្នឹងឡើងមកភ្នំពេញ ប៉ុន្តែអត់ដឹងថា គេយកប្រជាជនទៅណាទេ ។ ខ្ញុំចេះតែឆ្ងល់ខ្លួនឯង ប្រជាជនធ្លាប់រស់នៅគគ្រឹកគគ្រេង មិនដឹងជាប្រជាជនទៅណា ប៉ុន្តែមិនដឹងទៅតាមដាននរណា ។ ដល់ហើយយើងផ្ទុះចលនាមួយទៀត គឺវាយគ្នានៅស្រុកយួននៅឆ្នាំ ១៩៧៧ ។ កាលនោះសម្តេច ហ៊ុន សែន គាត់នៅមេបញ្ជាកងទ័ពដែរ នៅជាមួយយើងនេះ ប៉ុន្តែមើលទៅដូចថា ឃាតកម្មទៅលើប្រជាជនខ្លាំងពេក ។ គាត់ដឹង ហើយគាត់ក៏ដកខ្លួនចេញបាត់យើងអត់ដឹង ដល់នោះយើងផ្ទុះសង្គ្រាមវាយយួន ។ ខ្ញុំគេឲ្យទៅចេះតែទៅ មិនដឹងទៅវាយនរណា អត់បាយ ។ កាលពីជំនាន់នោះខ្ញុំនិយាយទៅវេទនា ខ្ញុំទៅវាយនៅមុខរត់មកក្រោយ គេបាញ់ពីក្រោយជួយ ។ ពេលនោះគេលែងទុកចិត្តគ្នា អស់ជំនឿគ្នា ច្របូកច្របល់ ខ្ញុំសម្រេចចិត្តដកខ្លួនជយ ។ គេចោទថាពួកខ្ញុំក្បត់ ខ្ញុំរត់ចេញពីកងទ័ព ហែលឆ្លងកាត់ទន្លេមេគង្គ អ្នកលឿង ។ គុណបុណ្យបុស្សីប្រវែងប្រហែលពីរម៉ែត្រ ។

ប៊ុនថន ៖ ពូរត់ទៅខាងណា?

ឆាយ ៖ រត់មកលិច ។ រត់ពីខាងស្វាយរៀង រត់តាមផ្លូវមកដល់អ្នកលឿង លោតក្រោមកំពង់ចម្លងអ្នកលឿង ហែលរហូតជិតដល់ពារាំងព្រោះទឹកហូរខ្លាំង យើងហែលផ្ងារ យើងបណ្តែតជង ។ គេហៅថាព្រែកដាច់ ចង់ដាច់ខ្យល់ ខ្ញុំហែលជិតមួយថ្ងៃ ខ្ញុំថាបើងាប់ៗចោះ កុំឲ្យវាបាញ់ ។ បានឆ្លងផុតមក នឹកឃើញថាធ្លាប់នៅភ្នំពេញ អញ្ចឹងរត់ចូលភ្នំពេល ។ មកដល់ធ្លាប់ស្គាល់មិត្តភក្តិ ក៏សុំគេចូលធ្វើកម្មកររោងចក្រកែវ ស៊ីងមានជ័យ ។ ទៅដល់នោះទៀត ធ្វើអីក៏អត់បានដែរ គេចោទថាយើងក្បត់រហូតមិនដឹងជាក្បត់រឿងអី ប្រុងយកខ្ញុំទៅវាយចោល ។ ខ្ញុំគិតខ្ញុំងាប់ហើយ ចៃដន្យគេថាយួនមកដល់ហើយ គេក៏ដកពួកកម្មករមកទប់នៅព្រែកក្តាម ។

ប៊ុនថន ៖ ពូឡើងវាយទៀត?

ឆាយ ៖ ខ្ញុំមកព្រែកក្តាម ប៉ុនអត់មានអាវុធទេ ។ ឆ្លងមកត្រើយម្ខាងហើយ កាលនោះគ្នាជាប់មួយពាន់យកទៅទម្លាក់ចោលខាងនោះ ខ្ញុំទៅនៅនោះ ។ គិតមើលតាំងពីព្រលឹម រហូតដល់ថ្ងៃត្រង់ បាយក៏មិនឲ្យស៊ី ហើយអាវុធក៏អត់មាន ហើយឲ្យចាំវាយ ។ ខ្ញុំសម្លឹងមើលទៅទិសខាងកើតក៏ឃើញកញ្ចក់រថក្រោះភ្លេត យើងដឹងតែគ្រោះថ្នាក់ហើយ ហើយខាងនោះក៏មិនដឹងថាយើងជាប្រជាជនឬជាទាហានដែរ ។ គេក្រឡេកឃើញយើង ក៏ផ្ដោងមក ប៉ុន្តែមិនឲ្យត្រូវគេគឺឲ្យធ្លាក់ក្នុងទឹក ។ យើងក៏រត់រូវទៅ ព្រោះយើងភ័យ គេក៏ឃើញមនុស្សច្រើន ក៏បាញ់មកលើយើងតែម្តង ។ ខ្ញុំលោតហែលឆ្លងព្រែក មកដល់កំពង់ចម្លងក៏ហែលមកទៀត ។ ឡើងពីទឹកមក មកចំផ្លូវចូលទៅភ្នំបាសិត កន្លែងហ្គារ៉ាស់សាំងឆេះ ។ ទៅមុខដល់ស្ពានជ្រោយចង្វារ

គេបាញ់ ក៏រត់មកវិញ ចេះតែមកៗ អត់បាយ ។ ខ្ញុំដើរកាត់ភ្នំទំរាំមកដល់បរេល ខ្ញុំរើសក្មេងតូចៗប្រហែល៣០នាក់មក ។ អស់អង្ករអីក៏ដោយ សុខចិត្តដើរដល់ភូមិមួយដែលគេរត់ចោលអស់អញ្ចឹង ខ្ញុំសន្សំស្រូវបុកឲ្យស៊ីតាមផ្លូវ ។ ខ្ញុំអាណិតក្មេងៗ វាឃំពេកខ្ញុំក៏រើសមក ។ ប៉ុនចេះចៃដន្យល្អដែរ ពេលនោះយួនវាមានចិត្តធម៌ម្យ៉ាងដែរ ប៉ុន្តែកន្លែងខ្លះមិនចិត្តធម៌ដែរ ។ ពួកខ្ញុំមកនោះសុទ្ធតែកូនក្មេង វាត្រៀមបាញ់ ហើយើងមកដល់គេអត់បាញ់ គេបើកផ្លូវឲ្យទៅ ។ យើងដើរអត់ដឹងគេនៅក្បែរហ្នឹងទេ ប៉ុនគេឃើញអាររម៉េករម៉ក់ ។

ប៊ុនថន : ពូស្លៀកពាក់ស៊ីវិល?

ឆាយ : ស៊ីវិល ។ យើងដើរអត់ដឹងនរណាទុកអី ដាក់អីឲ្យយើងទេ ។ ពេលដើរមកដល់ពាក់កណ្តាលផ្លូវឃើញអង្ករកន្ទះបាវ មានម្ហូបនៅផ្លូវ ។ យើងរកម្ចាស់មិនឃើញស្រែកសុំ ហើយកើបយកមកចិញ្ចឹមក្មេងៗ ។ ពីនោះមកដល់បរេលខ្ញុំរត់កន្លះខែ អត់បាយ ជាពិសេសអត់ទឹក វេទនាណាស់ ។ ក្មេងៗមកជាមួយខ្ញុំអត់មានងាប់ទេ មកដល់លាច ក្មេងៗខ្ញុំឲ្យទៅគេអស់ ។ ពួកខ្ញុំបានដើរមក ពេលនោះបានក្រមុំៗខ្លះ កូនក្មេងខ្លះដែលឲ្យទៅគេ ប៉ុន្តែវាអត់ទៅមកជាមួយខ្ញុំ ។ ខ្ញុំផ្ញើមេគេ កាលនោះអត់មានកាំភ្លើងមានអីទេ ប៉ុន្តែពាក់ពួកហ្នឹង ហែកក្រណាតសចងក្បាលកុំឲ្យគេបាញ់យើង ។ យើងដេកតាមផ្លូវយើងដើរ ហើយពេលនោះមកដល់តំបន់ភ្នំក្រុនចាញ់ បាន៥ថ្ងៃចាប់ផ្តើមស្លាប់ម្តង១ ម្តង២ រហូតដល់៥នៅហ្នឹងកន្លែងដេក ។ នរណាងើបរួចទៅមុខទៀត នរណាទៅមិនរួចនៅហ្នឹងកន្លែង ។ អត់មានប្រកាច់ទេ គឺដាច់ខ្យល់ស្លាប់នៅហ្នឹងកន្លែងតែម្តង ។

ប៊ុនថន : ស្លាប់ដោយសារអត់អាហារ ឬគ្រុន?

ឆាយ : គ្រុន ព្រោះអាហារពេលនោះមាន យ៉ាងហោចណាស់ក៏បានបបរឹងហូបដែរ ប៉ុន្តែស្លាប់ដោយសារអត់មានថ្នាំព្យាបាល ។ យប់ឡើង ខ្ញុំស្មាលាទោស ដេកចឹងខ្ញុំរំពាត់មួយ និងកូនក្មេងម្នាក់ថា អ្ហែងទៅជាមួយអញ ហៅវាមក ។ ខ្ញុំស្មាលាទោស មនុស្សស្រីយើងដល់ពេលដើរអត់ទឹកមិនដែលស្រួលទេ អត់ទឹកតែពីរថ្ងៃគ្នាចង់ងាប់ ព្រោះមនុស្សស្រីខុសពីមនុស្សប្រុស ។ មនុស្សប្រុសយើងស្លៀកខោខ្លីដើរបាន មនុស្សស្រីតែស្អុះស្អាប់ហើយ ដើរតែពីរថ្ងៃរលាកទាំងអស់ ដើរអត់រួចទេ ។ អញ្ចឹងដល់យប់ឡើង ខ្ញុំដើរមើល ។ គ្នាស្លៀកសំឡុយ ខ្ញុំឆ្លុលពិលមើល ស្មាលាទោសខែរងាររជងសំឡុយគ្របក្បាលទាំងអស់ ខាងក្រោមទៅណាទៅ ។ ខ្ញុំឃើញទាំងអស់ ខ្ញុំដើរទៅជួនណាខ្ញុំទាញគ្រប ខ្ញុំឃើញក្រណាត់ត្រង់ណាចេះតែរើសគ្របឲ្យទៅ ។ ហ្នឹងដាក់ស្ពែងខ្ញុំខ្ជួនឯងហើយ អត់មានកុហក់លាក់លៀមអីទេ ។ ខ្ញុំ

រៀបចំអស់ហើយ បាទខ្ញុំដើរមករហូត។ មកជាមួយខ្ញុំ១០០នាក់ មកដល់ម៉ាឡៃហ្នឹងនៅសល់តែ៣០នាក់ ហើយមកដល់ហ្នឹងអត់ហ្នឹងគោលដៅនៅខាងណាច្បាស់លាស់ទៀត។ ព្រៃច្រើនខ្ញុំរកកន្លែងអត់ឃើញទេ។ បាទបង ហុង អ្នកទទួលខុសត្រូវ គាត់ប្រកាសឲ្យទៅជួបគ្នានៅស្រែសាម៉ន មកពីរវៀរសឿ។ ទៅដល់គាត់ឲ្យនាំកម្លាំងទៅវិញទាំងស្រីទាំងប្រុសហ្នឹង គាត់ដកយកកម្លាំងទាំងអស់ គាត់លែងឲ្យនៅជាមួយខ្ញុំហើយ។ គាត់ចាត់តាំងខ្ញុំឲ្យមកនៅតាគង់ មកធ្វើឈ្លបនៅតាគង់ទៀត។ យួនបេះតែដេញមក ខ្ញុំបេះតែរត់ធ្លាក់ដល់ព្រំដែនថៃ។ ដើរមកដល់នេះគ្រែមរណៈមានចាំស្រេច នៅតែថ្ងៃស្លាប់ទេពួកខ្មែរក្រហមមួយពេលនោះ។ បោះគេដេញមកអស់ហើយ យួនមកនៅតាមព្រំដែនចឹង។ និយាយពីខ្មែរក្រហម ទីមួយស្បៀងក៏អត់មាន ថ្នាំពេទ្យក៏អត់មាន ហើយសម្លៀកបំពាក់ក៏អត់មាន ហើយការដេកពួនមុងអីក៏អត់មាន ជូនអីខ្លះកាច់មែកឈើក្រាលដេកទៅ ខ្លះបានទ្រនើរដេកទៅ។ ពេលបានអីហូប ម្នាក់យកតែព្រះអាយុរៀងខ្លួន ផ្អែតរៀងខ្លួនដើម្បីឲ្យរស់។ អត់មានថាបានហើយចែកគ្នានោះ គិតតែខ្លួនឯង អត់មានគិតអ្នកនេះអ្នកនោះទេ។ យើងឡើងមកនេះមកអត់រូប យួនវាយ។ យើងហូបគល់ចេញ មើមក្តួច ត្រពាំង គ្រាប់បេង។ អញ្ចឹងបានបងប្អូនយើងនៅក្នុងប្រទេសគាត់មិនថា ពួកខ្មែរក្រហមស៊ីស្លឹកឈើ។ គាត់ថាអត់ខុសមែន ខ្ញុំរស់ដោយសារត្រពាំង និងគ្រាប់បេងទុំ។ យើងយកមកលីងហើយ យកមកពុះគ្រាប់បេង រួចដាក់ស្ងោរនិងរម្ងាស់ឲ្យឡើងដូចបាយម៉ាន យើងចាក់ទឹកចោល។ យើងរម្ងាស់រហូតដល់អស់ជាតិអន្តាយ គ្រាប់បេងប៉ុនចង្កឹះ នៅសល់ប្រហែលប៉ុនចុងចង្កឹះ អានុះធ្វើជំនួសអង្ករ។ យើងយកត្រពាំងមកចិតលាយ ខ្ញុំរស់ដោយសារអាហ្នឹង។ ចឹងបានខ្មែរក្រហមស្គាល់អស់ ស្លឹកណាពុល ស្លឹកណាមិនពុល។ ពេលឡើងវាយម្តង ពេលមានគ្រោះថ្នាក់មានថ្នាំតិចបំផុត ប៉ុន្តែកាលវាយជំនាន់នោះមិនសូវមានគ្រោះថ្នាក់ទេ គ្រោះថ្នាក់ជាពិសេសគឺជំងឺគ្រុនចាញ់។ យើងឡើងវាយមិនសូវមានគ្រោះទេ ឡើងប្រឆាក បាញ់ដូងដាំង១ប្រុចទៅបាត់ អញ្ចឹងអត់មានគ្រោះថ្នាក់ទេ។ យើងឆ្នក់។

ប៊ុនថន : បាញ់ហើយរត់ទៅថៃ?

ឆាយ : រត់ចូលព្រៃ។ ពេលយើងនៅដីថៃនេះ តាមច្រកព្រំដែនយើងអត់វាយទេយើងចូលទៅក្នុង។ ដូចពីនេះទៅដល់ស្វាយស៊ីសុផុន ទៅវាយដល់ម៉ាជួរដងស្ទឹងយើងចូលទៅបេះ ហើយសុទ្ធតែព្រៃមាននរណាមើលឃើញ។ បើអ្នកវាយចូលដល់ក្នុងបានជួបប្រជាជន។ កាលយើងវាយដំបូងប្រជាជនខ្លាចខ្មែរក្រហមណាស់ គ្រាន់តែឡេកឃើញរត់។ ក្រោយមកយើងស្ទាក់គាត់

ជាប់ ហើយនិយាយល្អជាមួយគាត់ គាត់ចេះតែផ្ញើរបស់បន្តិចបន្តួចបានស៊ីខ្លះ ។ ប៉ុន្តែអ្នកនៅទីនេះចាំតែស្លាប់ហើយ អស់មានកម្លាំងតស៊ូទៀតហើយ ។ កាលនោះអត់មាននរណាយកប្រពន្ធនិងកូន គឺនៅលីវទាំងអស់គ្នា ។ នារីដឹកជញ្ជូនសុទ្ធតែក្រមុំ និងក្រមុំចាស់ ដេកជាមួយគ្នាប្រលែងគ្នា ។ អត់មាននរណាហ៊ានយកគ្រួសារទេ ដោយខ្លាចឥទ្ធិពលជំនាន់ខ្មែរក្រហម ។ កាលជំនាន់៣ឆ្នាំ មនុស្សប្រុសមនុស្សស្រីនិយាយគ្នាគឺអ្នកឯងក្បត់ ខូចសីលធម៌ យកទៅដាក់គុកឬសម្លាប់ចោល ប៉ុន្តែខ្ញុំអត់បានគេសម្លាប់ទេ ។ បើចាប់យកទៅខ្ញុំឃើញ នឹងដាក់ស្តែង ។ រហូតដល់ខ្ញុំទៅឃើញ នឹងរំដោះអ្នកទោសបាន ។ ទៅដល់កន្លែងនោះ ដូចគេដឹកត្រង់សេ បរិវេណធំហើយគ្រប់យ៉ាងស្អាត ខ្ញុំឆ្ងល់ព្រោះឃើញអ្នកយកបាយ ។ កន្លែងនោះបាំងស្អាតណាស់អត់មានអ្នកជាប់ទោសនៅទីនោះទេ ។ គំរបពីលើដូចតុ គេជាន់ពីលើផ្ទារមកហើយវាចូលយកបាយឲ្យស៊ី ។ ខ្ញុំមិនដឹងអី ខ្ញុំចេះតែឃើញយកបាយទៅ បាយតិច ហើយទឹកដាក់ពែងអាគោរ ។ អាចក៏ក្នុងហ្នុង នោមក៏ក្នុងហ្នុង ព្រោះគុកងងិត ប៉ុន្តែមិនដឹងនៅកន្លែងណា ខ្ញុំភ្លេចហើយ ។

ប៊ុនថន : ពូចូលទៅឃើញ?

ឆាយ : ឃើញគេយកបាយទៅខ្ញុំឆ្ងល់ថា អានោះយកបាយទៅណា តាមមើលអត់ឃើញព្រោះបាំងព្រៃ ។ ថ្ងៃនោះចៃដន្យម៉េច ខ្ញុំផាប់ៗចោះក៏ដើរទៅ ប៉ុន្តែមិនដឹងគន្លឹះដែលគេដាក់អែបដើមឈើ ។ ខ្ញុំរត់ទៅពួនដើមឈើខ្លាចគេឃើញ ក៏ប៉ះគន្លឹះវាលោតឡើងលើ ខ្ញុំអើតមើលទៅខ្ញុំហៅ ។ ក្នុងនោះជាប់៧នាក់ គ្រាន់តែបើកគេចេញមកហើយព្រោះស្មានយកអីឲ្យអីស៊ី ។ គេថាបងអើយជួយខ្ញុំផង ខ្ញុំថាម៉េច? គេថាខ្ញុំអត់ដឹងរឿងអីទេ គេយកខ្ញុំមកដាក់ក្នុងហ្នឹងហើយខ្ញុំក៏អត់មានដែរ ខ្ញុំថានៅហ្នឹងស្ងៀមទៅ ។ ខ្ញុំក៏បិទវិញ នៅជុំវិញមានដោតចម្រូងជុំវិញ ពេលនោះខ្ញុំមានកាំបិតភ្នោតសៀតនៅជាប់ចង្កេះ ។ ពេលនោះ ខ្ញុំប្រាប់ក្មេងៗដែលទៅជាមួយខ្ញុំថា អ្នកលូនបានត្រូវវាទៅដកចម្រូងចេញ អ្នកណានៅត្រូវនៅយាម ហើយធ្វើម៉េចរត់ឆ្លងស្ទឹងឲ្យដល់មុន ។ ម៉ោង១១យប់ ខ្ញុំលូនចេញមក ខ្ញុំប្រាប់ខាងនោះឲ្យត្រៀមអស់ហើយ ព្រោះនៅថ្មីៗនៅមានកម្លាំង ប៉ុនគេដាក់គុកពីថ្ងៃណាមកយើងអត់ដឹងទេ ។ គ្រាន់តែទ្វារបើកគ្រឹមខ្ញុំហៅចេញមក ប៉ុនគេអត់ដាក់ខ្នោះដៃទេ ព្រោះអាងតែនៅក្នុងដី និងគន្លឹះពីលើមានចេញទៅណារួច ។ ខ្ញុំនាំរត់ឆ្លងទៅដល់ត្រើយម្ខាង ពួកនោះផ្អើលបាញ់ ។ ខ្ញុំគិតថាយើងនៅអត់សុខទេ ទៅទៀតយើង ។ ខ្ញុំនាំរត់ឲ្យផុតពីកន្លែងដែលណាត់គ្នានៅស្ទឹង ។ ផុតពីស្ទឹងប្រហែលបីគីឡូទៅមុខ ខ្ញុំទៅនៅនោះឲ្យក្មេងៗទៅរកខ្ញុំនៅនោះ ។ បាននាំពួកនោះផុតទៅ

នៅនោះ ហើយដល់សួរទៅថាមានរឿងអ្វី? ថាអត់មានរឿងអ្វីទេ គ្រាន់តែបងប្អូននិយាយគ្នាមិនបាន គេចាប់យកដាក់ហ្នឹង ។ នោះប្រវត្តិខ្ញុំដែលរកឃើញ ។

ប៊ុនថន ៖ សុទ្ធតែប្រុស?

ឆាយ ៖ ប្រុស ។ ខ្ញុំនិយាយរឿងមួយទៀត កាលខ្ញុំមក ។ មកដល់ត្រពាំងជោរ ខាងត្បូងឪរ៉ាល់ កូនក្មេងកំពស់នេះ មិនដឹងគេបំពាក់ដល់ថ្នាក់ណា ។ វាយកក្ដាមមកសួរថា អានេះធ្វើពីអ្វី? ខ្ញុំស្ញើចចិត្ត ខ្ញុំរៀបបុកមួយកាំបិតឲ្យងាប់ ។

ប៊ុនថន ៖ សួរពូ?

ឆាយ ៖ បាទ ។ ខ្ញុំខឹងដល់ហើយចង់យកកាំបិតទៅបុកឲ្យងាប់ ប៉ុនគេមានកាំភ្លើង ។ យើងនិយាយបែក្រោយប៉ុណ្ណោះ អញ្ចឹងខ្ញុំនិយាយទៅមុខវិញ ។ ក្រោយពីតស៊ូនៅនេះហើយ ក្រោយពីមានការបន្តក់មកភ្លើងចេះតែរាលដាលវិញ បានធូរបន្តិចៗ ។ ហីនៅតាមតំបន់នេះ ពីដើមសុទ្ធព្រៃមែន ប៉ុន្តែបានបន្តក់បន្តិចៗព្រៃចេះតែវាលបន្តិចម្តងៗ ។ អ្នកតស៊ូចាប់ផ្តើមមានគ្រួសារ ពីឆ្នាំ១៩៨០មកមានហើយ ខាងលើគេឲ្យរៀបចំ ។ គេធ្វើផ្ទះនៅតាមព្រំដែន ប៉ុន្តែគេមិនធ្វើនៅក្នុងដីថៃទេ ធ្វើនៅដីខ្មែរ ។ អញ្ចឹងចាប់ផ្តើមកាប់ រីកៗ យូរៗដីកមកដាក់ដីខ្មែរទាំងអស់ ហើយយួនចេះតែដេញទៅដល់ភ្នំ ។ តំបន់នេះដេញអស់ហើយ យើងទៅនៅភ្នំ ។

ប៊ុនថន ៖ ភ្នំណា?

ឆាយ ៖ ភ្នំរូង ភ្នំម៉ាឡៃ ឲ្យតែឃើញភ្នំនៅតាមបណ្តោយព្រំដែន យើងដេញគេ ទៅនៅដល់ហ្នុងអស់ហើយ ។ អត់មានបាននៅនេះ យើងចេះតែវាយទៅ វាចេះតែរំកិលឡើងលើភ្នំ ។ វាចេះតែរីកៗបានគ្រាន់ទៅ ។ ជីវភាពអត់មានបានធូរធារទេ វានៅតែតឹងដូចគ្នា គ្រាន់តែយើងអាចហូបឆ្អែតមានកម្លាំង ។ បើមានបរបូរណ៍មិនមានទេ ហើយសម្ភារៈក៏ដូច្នេះដែរ ។ ការរស់នៅក៏មិនដឹងថាថ្ងៃណាវាយគ្រោះថ្នាក់ដល់ជីវិត ដល់កូន និងប្រពន្ធអញ់ទេ ។ ដេកទៅចេះតែរំពៃថាមិនដឹងពួកនោះមកវាយអញពេលណា ។ វាសប្បាយមែន ប៉ុន្តែសប្បាយក្នុងភ័យ ។ តែធ្វើម៉េចបើយើងរស់នៅក្រោមរបប ការគ្រប់គ្រងរបស់គេ បើយើងមិនធ្វើ គេថាយើងអញ្ចេះអញ្ចុះ ចឹងយើងត្រូវតែធ្វើ ។ នរណាមួយចង់កើតសង្គ្រាម មិនមែនចង់ទេ អ្នកដែលរត់មកទាំងអស់ អ្នករត់មកជាមួយខ្ញុំ អ្នកផ្សេងខុសពីខ្ញុំ ខ្ញុំសួរអស់ហើយថាយើងចង់កើតសង្គ្រាម ឬក៏ចង់ផ្សះផ្សា ។ ថាគេចង់ផ្សះផ្សា មិនកើតកើតសង្គ្រាមទេ ប៉ុន្តែយើងរស់នៅក្រោមរបបរបស់គេ ។ យើងធ្វើម៉េចទៅតតាំងជាមួយគេគឺរឿង ទៅអត់រួចទេដោយយើងអត់មានបង្អែក ។ ដល់ក្រោយៗមក ពេលធ្វើសមាហរណកម្ម កងទ័ពទាំងអស់គឺមានផ្លូវមួយ

ទៀត បានទាក់ទងជាមួយបងប្អូនទាហានយើងនៅខាងក្នុង បានចេញចូលទៅវិញទៅមកបាន។ យើងចង់ទៅលេងភូមិប្រាប់ទាហានគេ ប្រាប់ឈ្លបថា យើងចូលទៅលេងនោះហើយ អ្នែងការពារ ពួកនោះចូលទៅការពារអស់។ ឥឡូវគ្នាចង់ទៅលេងកន្លែងឯងវើយ មក១គឺថាអត់មានបញ្ហាទេ នោះទំនាក់ទំនងគ្នា។ មុនដំបូងបន្តិច១ទេ ប៉ុន្តែយូរទៅស្អិតរមួត ដល់ពេលខាងនោះប្រើឲ្យនាំយួនមកវាយខ្មែរក្រហម គេអូរមកប្រាប់ភ្លាមថា វើយគេឲ្យអញនាំទៅចំអ្នែងហើយនាំគ្នាដកចេញទៅ។ ពួកនោះនាំមកបាញ់កន្លែងហ្នឹង ហើយក៏ទៅវិញទៅ។ បើឥឡូវយើងចង់ទៅវាយ ប៉ុន្តែអត់វាយទេខ្មែរគ្នាឯង បើអត់យួនយើងអត់វាយ។ អញ្ចឹងបានសុខស្រួលនៅតាមដងស្ទឹង ម៉ាជំនាន់ដែលយើងចង់ប្របាច់បញ្ចូលគ្នា សុខតែម្តង អត់មានវាយគ្នាទេ។ កាលពីមុនដែលយើងមិនទាន់ទាក់ទងគ្នាបាន នៅក្រោមរបបដែលគេគ្រប់គ្រងយើង ពាក្យស្លោកដែលថា «បីកុំ»។ ពេលនោះដែលជល់គ្នា អត់មានដឹងថាខ្លួនអញងាប់នោះទេ អត់ដឹងកំព្រាកូន ប្រពន្ធ។ គេបំពាក់មាគ៌ាល្អមែនទែន មនុស្សទាំងអស់វាយគ្មានគិតទេ។ ប្រពន្ធនៅនេះ ប្តីទៅក្នុង ប្រពន្ធពោះធំ នៅតែថ្ងៃកើត។ ឧទាហរណ៍ថា គ្នា៨ខែហើយ ដល់ខែក្រោយកើតហើយ អត់ឲ្យនៅទេ ដេញឲ្យទៅបាត់។ ចោលប្រពន្ធ ទឹកភ្នែករហេមរហាម ប្តីទៅនោះជូនកាលប្តូទៅនោះ ប្រពន្ធកើតហើយ ប្តីងាប់ក៏មាន។ កាលនោះមនោគមន៍វិជ្ជាដែលគេបំពាក់មក ធ្វើឲ្យមនុស្សម្នាក់១មិនអាចគេចពីគេរួច ដោយសារយើងអត់បង្អែក អត់មានផ្លូវចេញ។ ដល់ក្រោយ យើងមានផ្លូវចេញហើយ ប្រើក៏យើងអត់ធ្វើដែរ។ បើជំនាន់នោះ ប្រៀបធៀបយើងធ្វើឥឡូវនេះដែលយើងធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលនោះវាខុសគ្នា បើយើងគិតជាភាគរយវិញ។ គេថាជំនាន់ខ្មែរក្រហមបានត្រឹមតែ ៨០ភាគដែលសប្បាយ ជំនាន់សម្តេច ហ៊ុន សែន នេះវាចូលដល់៩៩ភាគរយដែលសប្បាយ ហើយអត់មានគិតថាអានេះមកវាយអញ។ ខួរក្បាលយើងគិតថា យើងត្រូវបង្កបង្កើនផលដើម្បីចិញ្ចឹមជីវិត អត់មានគិតពីសង្គ្រាមអី។ រឿងនយោបាយរបស់មេដឹកនាំ។ បើនរណាជាប់ជាអ្នកដឹកនាំយើងទៅជាមួយអ្នកហ្នឹងទៅ កុំប្រឆាំង។ ឥឡូវវាសប្បាយ ចឹងបានន័យថាប្រជាជននៅកន្លែងនេះ យើងក៏មិនទាន់ដែរ ប៉ុន្តែជំនាន់ខ្មែរក្រហមវាច្រើនឥទ្ធិពល។ ក្រោយពីធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល និយាយពីក្បាលខ្ញុំចងរយះហើយចាប់សង្កត់ត្រង់ណោះ ងើបត្រង់នោះ វេទនាណាស់ទំរាំតែរៀបបានប៉ុណ្ណោះ។ ប៉ុន្តែនៅតែអត់បានស្រួលទៀត។

ប៊ុនថន : យ៉ាងម៉េចដែរ?

ឆាយ ៖ គាត់អត់ស្ដាប់យើងៗ យកមាគ៌ាដឹកនាំឥឡូវនេះមកដឹកនាំ គាត់អត់ស្ដាប់ទេ គាត់ស្ដាប់មាគ៌ាចាស់ៗ កាលពីជំនាន់ ប៉ុល ពត ខ្ញុំស្រលាញ់មាគ៌ាគាត់នោះមួយច្បាស់ល្អគឺ បំបាត់កុំឲ្យមានអំពើចោរកម្មៗ ល្អមែនទែន ហើយប្រដៅមនុស្សឲ្យត្រង់ល្អៗ បើមិនត្រង់ម៉េចមាគ៌ាឲ្យដើរត្រង់ទៅហ្នឹង អ្នកែតែងវកយកទៅវាយចោល អាណាមិនខ្លាចៗ ថាត្រង់គឺត្រង់ហើយ ហើយបើអានេះត្រង់ភ្លឹងហើយអាចោរមានអីងើប ងើបអត់រួចទេៗ ដល់ឥឡូវនេះចូលដល់ក្រោមការដឹកនាំរបស់សម្ដេច គេថាលក្ខណៈសេរី តែសេរីយើងសេរីប្រជាធិបតេយ្យ មិនមែនសេរីអាណាធិបតេយ្យទេៗ សេរីប្រជាធិបតេយ្យមានមេទទួលខុសត្រូវ ប៉ុន្តែសេរីអាណាធិបតេយ្យដោយឡែក អ្នកងទៅវាយក្បាលនរណាវាយចោះ យើងអត់មានទេសេរីនេះៗ យើងសេរីក៏ពិតមែន តែត្រូវចេះស្ដាប់មេៗ ប្រជាជនរស់នៅសព្វថ្ងៃនេះគាត់ចង់ឈានទៅសេរីអនាធិបតេយ្យ ប៉ុន្តែទៅអត់រួច យើងអូសមកវិញៗ អញ្ចឹងនៅរំពើកអាណាធិបតេយ្យ និងប្រជាធិបតេយ្យវាខុសគ្នាត្រង់ហ្នឹងៗ យើងចង់ឲ្យគាត់ស្គាល់មេណាដែលប្រគល់ឲ្យដឹកនាំ កុំឲ្យសេរីតាមអំពើចិត្តអ្នកឯង អត់បានទេនោះខុសច្បាប់ៗ អញ្ចឹងត្រូវទាញគាត់ឲ្យមកៗ វានៅពិបាកត្រង់នោះទេ ប៉ុន្តែប្រសិនបើបញ្ហាផ្សេងៗអាការរស់នៅអីរឿងធ្វើអីៗ គេគោរពតាមមាគ៌ាច្បាប់ដែលចែងមកៗ ខ្ញុំចង់និយាយពីប្រជាជនដែលគេសំណូមពរខ្ញុំថា ប៉ុនយើងអត់ធ្វើអីកើតទេ យើងបានតែសំណូមពរតទេៗ រាជរដ្ឋាភិបាលយើង ចំពោះប្រាក់កាសដែលយើងចាយថា ប្រាក់យើងថោកម្ល៉េះៗ ពីដើមលុយយើងមួយរៀលយើងដាក់តែលេខមួយទេ ប៉ុន្តែឥឡូវយើងថែមសូន្យពីរៗ អញ្ចឹងលុយយើងមួយរៀលនៅតែមួយរៀល ប៉ុន្តែគ្រាន់តែថែមសូន្យពីរ វាស្មើដូចលុយបរទេសទេ គ្រាន់តែថាលុយគេមួយរៀលស្មើលុយយើងមួយរយៗ បើសិនជាបូកលេខ គេមួយស្មើយើងមួយម៉ឺនៗ ប៉ុនគេចង់សំណូមពរថា ធ្វើម៉េចឲ្យលុយ និងថវិការយើងឲ្យថ្លៃៗ សំណូមពររាជរដ្ឋាភិបាលធ្វើម៉េចលុបបំបាត់អាលេខសូន្យឲ្យធ្លាក់មកនៅកន្លែងដើមវិញ ឲ្យមានតម្លៃៗ នៅតាមកន្លែងនេះប្រជាជនចង់រកអ្នកវិនិយោគណា ជាឥណទាន ដូរប្រាក់នៅកន្លែងនេះ គឺឲ្យប្រើតែលុយខ្មែរយើងៗ ប៉ុន្តែនៅទីនេះអត់ គឺនិយាយពីសេវា ប្រជាជនគាត់លំបាកណាស់ សេវាភ្លើងនេះស្រេចតែវាថា ចូលមកប្រទេសយើងហើយតើយើងផលិតលុយថៃបានទេៗ វាយកលុយថៃ ហើយវាយកថ្លៃទៀត ហើយរាជរដ្ឋាភិបាលឲ្យចាយលុយយើងៗ ដល់វានេះអាអ្នកឈ្នួញកណ្ដាលនេះឲ្យបង់លុយថៃឲ្យវា អញ្ចឹងចង់សំណូមពរឲ្យមានអ្នកវិនិយោគមកដាក់នៅហ្នឹងដើម្បីដាក់ធនាគារដើម្បីដូរប្រាក់ៗ ឧទាហរណ៍ថា ថៃចង់ចូលប្រទេសយើង អ្នកង

ត្រូវដូរឲ្យហើយ ធនាគារដូរឲ្យហើយ ចង់ដូរដុល្លារហើយ ចូលទៅលេងចុះ ។ កុំឲ្យវាយក លុយថៃ ស្រេចតែវាថា ហាងឆេងនៅមាត់វា ។ អញ្ចឹងប្រជាជនគាត់លំបាកណាស់ ។ ការរស់នៅសព្វថ្ងៃនេះ គាត់គាំទ្រទាំងស្រុករបស់របសម្ដេចនាយក ភាគច្រើននៅនេះខ្ញុំនិយាយមួយម៉ាត់ថា វាប៉ះពាល់បន្តិចផ្នែកនយោបាយ និងផ្នែកគណបក្ស ។ ឧទាហរណ៍ ១០០ វាទៅអស់៩៩.៩ភាគរយ ក្នុងការដឹកនាំ ព្រោះគេមើលឃើញពីការដឹកនាំ និងមាគ៌ារបស់គាត់ ។ យើងគិតថា បើយើងធ្វើសង្គ្រាមជាមួយថៃយើងធ្វើណាស់ហើយ ប្រាសាទព្រះវិហារនោះ វាយគ្នាបាត់ហើយ ក៏ប៉ុន្តែជំហរអ្នកដឹកនាំយើងមិនធម្មតាទេដូចសម្ដេចនាយកនេះ រកមិនបានទេនៅលើសកលលោក ។ ខ្ញុំថាឲ្យដើររកទៅមិនបានទេ ឆ្ងៀសវៃហើយ គេហៅថាមានអំណត់អត់ធន់ណាស់ ធ្វើភ្លៀងផ្គរម៉េចយើងនៅស្ងៀម ។ ប៉ុន្តែស្ងៀមនេះមិនឲ្យគេជាន់ទេណា ។ ចឹងបានថា ម្នាក់ៗគេស្រលាញ់មាគ៌ានេះ គេមិនចង់ឲ្យកើតសង្គ្រាមឲ្យមានខ្មែរក្រហមវិញ ឬក៏មានខ្មែរស អត់ដាច់ខាត បដិសេធមិនឲ្យមាន ។ គេរស់នៅបានស្រួលហើយ បានសុខហើយ គេលែងហើយ ។ ជម្រាបប្រវត្តិសង្ខេបខ្លីៗ បើសៀវភៅឲ្យកត់ ១៤ទៅ១៥ក្បាល ។

ប៊ុនថន : ពូតស៊ូច្រើនឆ្នាំចឹងពូដឹង?

ឆាយ : ដឹងពីណាធ្វើអី ពីណាដឹកនាំអីក៏ខ្ញុំដឹងដែរ ប៉ុន្តែយើងមិនដឹងពីផ្ទៃក្នុងគេ ។ ជំនាន់ដឹកនាំគេកាលនោះ ប៉ុល ពត តាម៉ុក នួន ជា អៀង សារី ខៀវ សំផន ហើយ វន វ៉េត សុទ្ធតែចង្កោមគេនោះ ។ ខ្ញុំដឹង ហើយស្គាល់ទាំងអស់ ក៏ប៉ុន្តែមិនដឹងគេដឹកនាំខាង អាណាបញ្ជាធ្វើអីៗ ។ ដឹងដែរ ប៉ុន្តែខ្ញុំគាំទ្រតែមនុស្សតែម្នាក់ទេ ដែលគាត់អត់ដឹងមែន ។ ពីរនាក់ដែលរស់នៅសព្វថ្ងៃនេះ ។ ខ្ញុំទទួលស្គាល់ថាគាត់អត់ដឹងរឿងអីទេ ដូចតា ខៀវ សំផន និង អៀង សារី ។ អៀង សារី គាត់ខាងក្រសួងការបរទេស គាត់ដឹងតែរឿងការបរទេស ខាងក្នុងល្អក់កករម៉េចគាត់អត់ដឹងទេ ។ ខៀវ សំផន គាត់គណប្រធានរដ្ឋមែន គ្រាន់តែជាបង្គោលនោះ អត់ដឹងអីទេ ។ គ្រាន់តែថាការងារ ចង់សម្រេចការងារសួរតា ខៀវ សំផន ។ ពីរនាក់នោះខ្ញុំជឿថា គាត់បរិសុទ្ធ អត់មានការប៉ះពាល់ការសម្លាប់នរណា គាត់អត់ដឹងរឿងទេ ប៉ុន្តែក្រៅពីនោះគេម៉េច ខ្ញុំអត់ដឹងទេ ។ ខ្ញុំជម្រាបឲ្យគ្រង់ព្រោះខ្ញុំរស់នៅខ្ញុំដឹងហើយ ប្រវត្តិតាៗទាំងអស់ ហើយតាៗទាំងអស់ក៏មិនបងខ្ញុំប៉ុន្មានដែរ យ៉ាងច្រើនបងខ្ញុំ២០ទៅ២៥ឆ្នាំយ៉ាងច្រើន ។ តា ខៀវ សំផន បងខ្ញុំប៉ុន្មានយ៉ាងច្រើនថាគាត់៧០ឆ្នាំ ។

ប៊ុនថន : ពូ ស្រុកកំណើតនៅណា?

ឆាយ ៖ ស្រុកស្អាង ។

ប៊ុនថន ៖ ភូមិអី?

ឆាយ ៖ ភូមិព្រែកពោធិ ឃុំទឹកវិល ជាប់នឹងវត្តចុងកោះ ។

ប៊ុនថន ៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ឆាយ ៖ បងប្អូនទាំងអស់៧នាក់ ។ ប៉ុន្តែខ្ញុំមិនចង់និយាយ ដំនាន់នោះមានកំហឹងនៅក្នុងខ្លួន ។ ប្អូនស្រីខ្ញុំ ម្តាយខ្ញុំ គេយកមកសម្លាប់ចោលនៅកោះគ ។ ឯប្អូនខ្ញុំពីរនាក់ទៀតបាត់ខ្លួន មិនដឹងគេសម្លាប់ចោល ឬទៅណាដែរ ។ ឥឡូវខ្ញុំសល់តែប្អូននាក់ទេ ។ នៅបងស្រីមួយ ខ្ញុំមួយ និងបន្ទាប់ប្អូនពៅដែលគេយកទៅសម្លាប់ចោលនោះពីរនាក់ ។ នៅអាទី និងទីមួយ អាទី៧ស្លាប់ហើយ ។ បាត់អាទី៣ និងទី៤ ។

ប៊ុនថន ៖ ពូទីប៉ុន្មាន?

ឆាយ ៖ ខ្ញុំទី២ ។ អញ្ចឹងបានខ្ញុំមានកំហឹងខ្លាំងណាស់ ។

ប៊ុនថន ៖ បងប្អូនលោកពូនៅកោះធំ?

ឆាយ ៖ នៅស្រុកស្អាង នៅវត្តចុងកោះ ឃុំទឹកវិល ។ ខ្ញុំអត់ទៅ តែទៅឃើញមុខគេដឹងថា ទ្រាំមិនបាន ។ ខ្ញុំកាលទៅលើកមុនម្តង បងស្រីខ្ញុំចាប់ ។ ខ្ញុំប្តេជ្ញាថាងាប់នៅស្រុក ខ្ញុំទាញកាំបិតដេញកាប់ ។ ខ្ញុំលែងទៅរហូតដល់ឥឡូវ ។ ម្តាយអត់មានរឿងអីយកទៅសម្លាប់ចោល ។

ប៊ុនថន ៖ ពូចូលរៀននៅសាលាណា?

ឆាយ ៖ រៀននៅសាលាវត្តចុងចោះ ហើយដល់រៀនចប់ ប្រលងជាប់អនុវិទ្យាល័យចូលរៀននៅសាលាស្រុកស្អាង ។

ប៊ុនថន ៖ ចូលរៀនយូរទេ?

ឆាយ ៖ តាំងពីថ្នាក់កុមារដ្ឋាន ខ្ញុំរៀនបានប្រាំបីឆ្នាំ អត់មានឌុបថ្នាក់អីទេ ។ ហើយដល់ប្រលងចូលថ្នាក់ទី៦ អនុវិទ្យាល័យ ខ្ញុំជាប់លេខ១ ។ គ្រូនៅសាលាស្រុកស្អាងសុំទិញឈ្មោះដាក់ឲ្យកូនគាត់ ។ សុំទិញឈ្មោះ ចង់បានអីឲ្យទាំងអស់ ។ ជីវភាពម្តាយខ្ញុំមិនជាក្រអីទេ វាកណ្តាលឲ្យកូនរៀន ប៉ុន្តែខ្ញុំគិតថាធ្វើបាបម្តាយ ។ បើគេទិញៗចោះ ប៉ុនខ្ញុំយកឈ្មោះគេមករៀនដដែល យើងបានលុយនោះចាយ ហើយចៅហ្វាយស្រុកគេខត្តម្ត ចង់ទិញម៉ូតូទិញឲ្យ ។ ក្នុងមួយខែគាត់កំណត់ឲ្យអង្ករម្តាយខ្ញុំមួយបាវ ឲ្យតែខ្ញុំនៅរៀនជាមួយកូនគាត់ ដេកជាមួយកូនគាត់នៅសាលាស្រុក ជួយបង្រៀនកូនគាត់ ។ បានពាក់កណ្តាលឆ្នាំ ខ្ញុំឈប់ ។

ប៊ុនថន ៖ ម៉េចបានឈប់?

ឆាយ ៖ បោះឆ្នាំ១៩៧៩ ពូសួរល្មៀង១ ខ្លាចបែកម៉ែ ។

ប៊ុនថន ៖ ពូឈប់រៀនហើយទៅណា?

ឆាយ ៖ មកនៅផ្ទះ តែដោយសារជីវភាព ខ្ញុំមកនៅភ្នំពេញ ។ កាលនោះមិនទាន់មានសង្គ្រាមទេ ។ មកស៊ីឈ្នួលចិនបានមួយខែ កាលនោះចិនស្រាឡាញ់ខ្ញុំ ចិននោះមានកូនក្រមុំពីរនាក់ ។ ទៅនៅនោះអត់មានធ្វើអ្វីទេ គេប្រគល់ភារកិច្ចឲ្យទាំងអស់ គេឲ្យជូនកូនចៅគេដើរលេង ។ កាលពីដើមឡានគេម៉ាកកាត់សងកាត់នោះ ល្អជាងគេ ស្អាតជាងគេ ។ ទិញឡាននោះឲ្យបើកដើរ ហើយបើស្រលាញ់កូនគាត់មួយណា យកមួយនោះទៅ ។ កាលនោះខ្ញុំស្រលាញ់ប្អូន តែបងមិនឲ្យខ្ញុំយក ឲ្យយកវាវិញ ហើយបើទៅណាទៅទាំងពីនាក់ ។ ខ្ញុំគិតថាមិនស្រួល ក៏ទិញអង្ករដាក់ឡានយកមកឲ្យម្ដាយ ហើយត្រឡប់មកវិញ ។ មកដល់២-៣ថ្ងៃ ស្រាប់តែពូសួរគ្រិលខ្ញុំទុកឡានហើយរត់ទៅ ទៅដល់ម៉ែគាត់ក៏រត់ទៅដែរ ព្រោះគាត់ខ្លាចសង្គ្រាម ។ គាត់រត់ទៅពួនបាត់ រកគាត់មិនឃើញ ។ ទាំងផ្ទះៗរត់ទៅពួននៅក្នុងព្រៃ ។ ដល់ពេលយប់មកដេកនៅផ្ទះ គេឡើងមកវាយនៅសាលាស្រុកអត់ដឹង គេវាយទៅយើងជាប់នៅហ្នឹងទាំងអស់ ។

ប៊ុនថន ៖ ខាងណាវាយ?

ឆាយ ៖ ខាងយួន ។ ព្រលឹមឡើងឃើញយួននៅជុំវិញផ្ទះ ។

ប៊ុនថន ៖ យួនខាងណា?

ឆាយ ៖ យៀកកុង យួនវៀ ។

ប៊ុនថន ៖ កាលពូមកផ្ទះចិនធ្វើអី?

ឆាយ ៖ ធ្វើនំប័ុង គ្រាន់តែទៅជួយរៀបនំអីឲ្យគេ ។ ឈ្នួលចាស់គេអ្នកធ្វើទាំងអស់ ។ យើងដូចជាចៅកែ ។

ប៊ុនថន ៖ ពូរត់ចេញទៅនៅជាមួយម្ដាយ ។ ចុះគ្រួសារគាត់ទៅនៅណា?

ឆាយ ៖ គាត់នៅភ្នំពេញដដែល ព្រោះមិនទាន់រត់ទេ ។ កាលឆ្នាំ១៩៧៥ ខ្ញុំធ្វើទ័ពមានឥទ្ធិពល បើគិតមកដល់ឥឡូវខ្ញុំសក្តិបួន ។ ខ្ញុំតាមរកគាត់ដែរ យើងមកចាំផ្លូវខាងនេះ គាត់ចេញទៅខាងនោះ ។ ពូសួរថាគេឲ្យទៅខាងនោះ តាមទៅរកអត់ឃើញទៀត ។ ដល់ពេលយូរក្រោយមកបានពូសួរដំណឹងថា ចិននោះគេឲ្យមកតាមផ្លូវជាតិលេខ៣ ហើយមកហួសចោមចៅគាត់ស្លាប់ ។ ស្លាប់នៅផ្លូវ អត់មាននរណាធ្វើបាបគាត់ទេ កាលនោះខ្ញុំស៊ើបអ្នកនៅ លន់ នល់ ដែលដកពីកន្លែងមួយទៅកន្លែងមួយ ។ ហើយកូនទាំងពីរនាក់នោះ ក្រោយមកពូសួរថាមានប្ដីទាំងពីរ គ្រាន់តែពូថាមានប្ដីហើយ ខ្ញុំលែងសួរហើយ ។ មិនដឹងជាទៅណាទេ ។

ប៊ុនថន ៖ ម៉េចបានពូតាមរកគាត់?

ឆាយ ៖ នឹកឃើញថា គាត់ធ្លាប់អាណិតស្រឡាញ់យើង យើងមិនភ្លេចគុណគាត់ទេ។ យើងតាមរកគាត់ រកឃើញមិនឃើញ ប៉ុន្តែយើងតាម។ ខ្ញុំតាមរកគាត់ដែរ តែមិនឃើញ។ កាលនោះខ្ញុំមានអំណាចដែរ តែមិនដឹងថាគេសម្លាប់មនុស្សម៉េចទេ។ ឧទាហរណ៍ ខ្ញុំនាំកងទ័ពទៅខាងត្បូង អត់ឃើញមានអី បាយទឹកឃើញមានស៊ីបរបូរណ៍ អត់ឃើញមានប្រជាជនណាមកខ្សិបថាគេវាយមនុស្សចោល។ ពេលដើរទៅមើលតាមព្រៃអត់មានធំក្លិនអីទេ។ ដល់ពេលវាយឯករាជ្យ ក្រោមការដឹកនាំរបស់សម្តេចនាយកហើយ ម៉េចក៏មានឃាតកម្មអីច្រើនម៉្លេះខ្ញុំឆ្ងល់។ កាលដំបូងខ្ញុំប្រឆាំងថា មិនដែលខ្មែរក្រហមណាវាយមនុស្សសម្បើមម៉្លេះ ពួកនោះវាប្រឌិតខ្លួនវា។ កាលនោះខ្ញុំនៅក្នុងព្រៃអត់ដឹងរឿងច្បាស់ ខ្ញុំថាពួកនោះប្រឌិតសន្ធំរឿងវាយគ្នាសាប់ទៀតហើយ។ ក្រោយមកខ្ញុំអានតាមការសែត ហើយសម្តេចនាយកពីការកាត់ទោស ប្រហែលជាមែនហើយព្រោះម្តាយខ្ញុំគេយកវាយចោលដែរ។ កាលនោះឲ្យតែអ្នកមានភារកិច្ចល្មមអត់ដឹងសោះ ដូចថាកន្លែងនេះគេសម្លាប់មនុស្ស យើងចុះមកដល់ស្ងាត់ឲ្យឃើញ អត់មានពីណាយកទេ។ យើងទៅវិញគេធ្វើដដែល ព្រោះមានពីណាទៅដឹក មើលឃើញ។ យើងផ្ញើទស្សនកិច្ចតែនៅខាងក្រៅ ប៉ុនផ្ទៃក្នុងដឹងយ៉ាងណា។

ប៊ុនថន ៖ ពូទៅនៅជាមួយម្តាយបានប៉ុន្មាន?

ឆាយ ៖ ទៅនៅបានពីរខែ គេវាយចូលមក ហើយអូសខ្ញុំយកទៅបាត់។

ប៊ុនថន ៖ ខាងណាអូសទៅ?

ឆាយ ៖ វៀតណាម។ កាលនោះ គេមានទំនាក់ទំនងម្តាយខ្ញុំ កាលនោះគេថា បែឲ្យអាអូនទៅនៅជាមួយទៅ។ កាលនោះខ្ញុំសរសើរគេដែរ កាលនោះមេគេឈ្មោះ ដូវ ប្រាប់ម្តាយខ្ញុំថា ឲ្យអាអូនទៅនៅជាមួយខ្ញុំ ខ្ញុំអត់ឲ្យធ្វើអីទេ គឺឲ្យតែជិះម៉ូតូជាមួយខ្ញុំ។ ហើយស្រីពៅយួនកាលនោះ ក្រមុំស្អាតៗណាស់។ កាលនោះជិះម៉ូតូជាមួយវា ទៅដល់កន្លែងសម្រាក ស្រីយួនមកដល់ពរ តែយើងធំវាពរមិនរួច វាឱបយើងទៅមុជទឹកដុះសាប៊ូឲ្យ។ ដល់ពេលយប់ចងមុងឲ្យដេកទៀត។ ស្រីៗនោះការពារយើងណាស។

ប៊ុនថន ៖ កាលនោះពូអាយុប៉ុន្មាន?

ឆាយ ៖ ខ្ញុំអាយុ១៥-១៦ ប៉ុន្តែវាក្រេះ។ ប៉ុនពេលទៅនៅជាមួយយួននោះ ខ្ញុំមិនឲ្យស្លៀកពាក់ឲ្យខ្ញុំទេ។ ខ្ញុំរៀនដល់ថ្នាក់វិទ្យាល័យ យើងខ្មាស់គេ។ ខ្ញុំនៅជាមួយយួនបាន៦-៧ខែ ខ្ញុំធំ ដូចថាត្រូវដី ស្ទុះកំពស់ឡើង។ បែកគំនិតរត់ចេញពីយួន មកបង្ករបក្សពួកនៅស្រុកស្អាង។

ខាងគេបន្តរបានខ្លះ ខាងខ្ញុំបន្តរបានខ្លះ ប្របាច់បញ្ចូលគ្នា ។ ទល់ខ្ទង់គ្នា បង្កើតបានតំបន់ ២៥ ។ ប៉ុនឥឡូវលែងតំបន់២៥ហើយ គេដាក់ខេត្តកណ្ដាល ។

ប៊ុនថន : ពូរត់មកនៅខាងខ្មែរ?

ឆាយ : ខាងខ្មែរ ។ កាលពីដើមគណៈតំបន់ឈ្មោះ តាសុក ។ ឥឡូវទៅសួរថា កាលពីជំនាន់ខ្មែរក្រហម ក្រោយពីគេរំលាយខេត្តអាងយ៉ាងចេញ តើតំបន់ហ្នឹងគេដាក់តំបន់អី? គេដាក់ខេត្តអាងយ៉ាង តំបន់៦២ ។ តែខ្ញុំក្រោយពីនោះមករំសាយចោល ដាក់តំបន់២៥ ហើយគណៈតំបន់ឈ្មោះ តាសុក ។

ប៊ុនថន : ពូរត់ចេញពីនោះមកនៅជាមួយនរណា?

ឆាយ : អត់នៅជាមួយនរណាទេ ។ ឧបមារ គ្នាយើង នោះស្គាល់មួយ នេះស្គាល់មួយទៅ យើងរួមគ្នាបង្កើត ។ ទៅអូនទាញកូនប្រជាជនមកចូលរួម តែមិនមែនចូលរួមចំហឲ្យមានអាវុធកាន់ទេ គឺយើងលាក់ខ្លួន ហើយយើងនៅផ្ទះធម្មតា ។ តែយួនប្រហែសយើងលួចកាំភ្លើង រួចហើយយកទៅទុករបស់យើង ។ ពេលបានកាំភ្លើងច្រើនហើយ បំពាក់អាវុធហើយ កាងដាក់គ្នា ។

ប៊ុនថន : នរណាដឹកនាំ?

ឆាយ : អត់មាននរណាដឹកនាំទេ ។ កាលនោះមានមេរបស់ខ្ញុំមួយ គាត់ស្លាប់ហើយ ។ ឈ្មោះ គាត់កំណើតនៅផ្ទះនោះឈ្មោះ សៀវ ប៉ុន្តែពេលចេញទៅបដិវត្ត គាត់ដាក់ ណុប សន្តិភាព ។ ពេលគាត់ឡើងមកវាយនៅសិត្បូវ គាត់ត្រូវគ្រាប់សីវ៉ែនធីណាញ ។ គាត់ដាច់ពោះវៀនពីរបីកង់ ក៏ត ។ ក្រោយមកមីងគាត់ទៅលេង ថ្ងៃខ្ញុំទីមួយគាត់ដើបឡើងមក ដាច់ថ្នេរមួយសារ ។ ក្រោយមកចង់ជាហើយ តែឃើញបងមកស្ទុះភ្លេតមក ហើយអាក្រៅនោះអត់ដាច់ តែដាច់ពោះវៀនក្នុង ។ អត់ដឹង ក៏ស្លាប់ទៅ ។ កាលជំនាន់នោះមានតែគាត់ទេ ដែលធ្វើដឹកនាំ ។ ក្រោយមកចេះតែបំបែក អានេះធ្វើកងនេះ អានោះធ្វើកងវរនោះ ក្រោមការដឹកនាំរបស់តាសុក ទាំងអស់ ។

ប៊ុនថន : ពូនៅកងវរណា?

ឆាយ : ខ្ញុំនៅវរ១៩ កងតូច៩៣ ខ្ញុំនៅប្រចាំការនៅសិត្បូវ ។ នៅកំពង់ចម្លងដើមព្រីងរហូត ។

ប៊ុនថន : អត់មានផ្លាស់ប្ដូរទេ?

ឆាយ : អត់ទេ ។ ខ្ញុំវាយច្រើនណាស់ ។ ខ្ញុំវាយនៅទន្លេមេគង្គ ក្បូនធំៗ ។ ពេលនោះខ្ញុំទៅនៅជាមួយ តាកាត មេបញ្ជាការទ័ពស្រុក ។ ទៅវាយការទន្លេមេគង ទៅវាយដាក់ក្បូនប៊ុស្សីបណ្ដែតកាត់ទន្លេមេគង្គដើម្បីទាក់កប៉ាល់ អាហ្នឹងពួកខ្ញុំអ្នកដាក់ ។

ប៊ុនថន : ពូនៅជាមួយ កាត រួចឡើងទៅវ៉ាយចល័ត?

ឆាយ : ខ្ញុំមកពីមួយហើយ ខ្ញុំមកនៅនេះមួយរយៈ រួចហើយទៅនៅជាមួយ តាកាត ។ ខ្ញុំទៅជាមួយ តាកាត អស់ចិត្តហើយ បានដកខ្លួនមកនៅទីនេះ ។ ខ្ញុំមកនៅជាមួយមាឈ្មោះ សៀ ដឹកនាំកង់ទ័ពឡើងវ៉ាយ ។ ដល់មាស្លាប់ទៅ ក៏ខ្ញុំនៅតែហ្នឹង ។

ប៊ុនថន : នៅកងវរ?

ឆាយ : នៅកងវររហូត ជំនួសមុខគាត់ ។

ប៊ុនថន : វ៉ាយនៅណាខ្លះ?

ឆាយ : ខ្ញុំមកវ៉ាយនៅកំបូលបែកចាន ២៥ នេះ ។ មកតាមខេត្តតាកែវ មកតាមភ្នំ១០០ស្រទាប់ រហូតចេញមកតាមផ្លូវលេខ៤ ។ មកតាមវត្តអង្គជុំ ព្រៃរមៀត ឡើងមកសៀវមកកំបូល មកជ្រុងភ្នំពេញ ជ្រុងពោធិចិនតុង ។ តែលើកកញ្ជើរវ៉ាយហើយមិនដែលបានសុខទេ?

ប៊ុនថន : យ៉ាំងម៉េចវិញ?

ឆាយ : ឧទាហរណ៍ថា កងទ័ពទៅ១០០នាក់អញ្ចឹង ។ ទៅវ៉ាយរបេះអស់ពីរបីទៅ ហើយទៅទីនោះរបេះពីរបីទៀតទៅ ព្រោះអត់ស្គាល់ភូមិសាស្ត្រ តែបើដឹងភូមិសាស្ត្រខ្លួនឯងអត់មានអីទេ ។

ប៊ុនថន : គេចាត់តាំងឲ្យពូឡើងវ៉ាយ?

ឆាយ : ចាត់តាំង ។ គេថាម៉េចកងពិសេសនោះ គឺកន្លែងណាដែលតឹងគេបញ្ជូនឲ្យឡើងទៅវ៉ាយ ។ មិនមែនចេះទៅសុំវ៉ាយទេ ព្រោះនៅឆ្ងាយ ។ ឧទាហរណ៍ថា ផ្ទះនេះជាខ្មាំង មិនមែនកងនេះសុំទៅវ៉ាយ ឬកងនោះសុំទៅវ៉ាយបានទេ គឺប៉ុន្មានមុខសញ្ញានេះត្រូវស៊ើបការទាំងអស់គ្នា ។ នរណាគេស៊ើបបានច្បាស់ជាង យកមកដាក់វិភាគគ្នា ដូចជាឈ្មោះក ស៊ើបឃើញទាហានប៉ុន្មាន កាំភ្លើងអីត្រង់ណា មានប៉ុន្មាន ។ វិភាគឃើញឈ្មោះកស៊ើនឃើញច្បាស់ជាង គេចូលច្រកនេះអាចស៊ីបាន ចូលច្រកនោះគ្រោះថ្នាក់ ។ ពេលនោះអ្នកដែលស្និតបំផុតនោះ គេចាត់តាំងឲ្យទៅវ៉ាយ ដល់ហើយគេជញ្ជូនគ្រាប់ឲ្យវ៉ាយតែម្ដង ។

ប៊ុនថន : ពូនៅកងវរនោះរហូតដល់ដាច់ភ្នំពេញ?

ឆាយ : នៅរហូតដល់ឈប់ រត់មកនៅកម្មករ ។

ប៊ុនថន : ដាច់ភ្នំពេញពូចូលទៅខាងណា?

ឆាយ : នៅខាងទ័ពនោះដដែល ។ ពួកខ្ញុំគេឲ្យមកនៅខាងផ្លូវទឹកល្អក ។ អីចឹងបានខ្ញុំឆ្ងល់ ដឹងមនុស្សចះតែបាត់ទៅណា ។ ក្រោយមកខ្ញុំដឹងថា វ៉ាយគ្នានៅឯកើត នៅស្វាយរៀង គេហៅថាវ៉ាយតែនីញ ។ ហ្នឹងមានបទបញ្ជាឲ្យទៅនោះទៀត ដល់ឃើញសភាពការណ៍មិនស្រួលរត់

ឈប់ពីកងទ័ពមកនៅជាកម្មករវិញ ។ ជៀសផុតពីទាហាន ក៏នៅដដែល បញ្ជូនទៅព្រៃកក្តាមទៀត ។

ប៊ុនថន : ពូនៅកងពលលេខប៉ុន្មាន នៅទឹកល្អក?

ឆាយ : កងពលលេខពី១២ មេនោះ តាពីស ឬ តាណាត ខ្ញុំភ្លេចឈ្មោះព្រោះយូរណាស់ហើយ ។ កាលនៅកងពលនោះ ខ្ញុំមិនទាន់កងពិសេសទេ គឺនៅជាយុទ្ធជន អង្គភាពជាមួយគ្នាទេ ។ ដល់ក្រោយមក វាយជិតដល់ភ្នំពេញហ្នឹង បានគេដកខ្ញុំពីកងពលលេខ១២មកនៅជាកងពិសេស ។ កងពិសេសនោះ មិនទាន់ប្រថាប់ត្រាទេ គ្រាន់តែគេដាក់ថា កងពិសេសប្រចាំភូមិភាគ ។

ប៊ុនថន : ភូមិភាគណា?

ឆាយ : ភូមិភាគនិរតី ហើយក៏មិនដឹងថានរណាជាមេទទួលខុសត្រូវភូមិភាគនោះទៀត ។

ប៊ុនថន : ពេលនៅភ្នំពេញពូនៅកងពិសេសដដែល?

ឆាយ : នៅកងពិសេស រហូតដល់ធ្លាក់ទឹកទន្លេភ្នំពេញ ទើបឈប់ ។

ប៊ុនថន : ប៉ុន្តែមានដឹងនរណាគ្រប់គ្រងទេ ។

ឆាយ : កាលនៅកងពិសេសនោះ ពិសេសភូមិភាគនៅនិរតីគ្រប់គ្រងដដែល ។ ប៉ុន្តែដាច់ពេលខ្ញុំមកធ្វើកម្មករ ហើយហែលធ្លាក់ទឹកទន្លេព្រែកទើបឈប់ ។

ប៊ុនថន : ពូមកនៅទឹកថ្លាបានរយៈពេលប៉ុន្មានទើបឡើងទៅវាយ?

ឆាយ : យូរដែរ គឺ៧៥,៧៦ និង៧៧ ទើបឡើងទៅវាយ ។ ប៉ុន្តែពេលមកនៅហ្នឹងអត់មានធ្វើអីគឺដេកស៊ី ។

ប៊ុនថន : ពូឃើញទិដ្ឋភាពនៅភ្នំពេញយ៉ាងម៉េច?

ឆាយ : ខ្ញុំធ្លាប់នៅពីដើម ឃើញមនុស្សកុះករ ប៉ុន្តែពីដើមមិនដូចឥឡូវនេះទេ ។ មានឡានទៅមកច្រើន ។ ពេលវាយចូលដល់ភ្នំពេញ ឃើញឡាននិងមនុស្សច្រើន ស្រាប់តែមួយថ្ងៃស្ងាត់បន្តិចៗ ។ ប្រហែលមួយខែឃើញតែកងទ័ពដើរ អត់ឃើញប្រជាជនទេ ។ កងទ័ពឡើងទៅផ្ទះនេះ ទៅនោះពួកគេក្តាំង ។ ខ្ញុំនៅតែខ្វែងមិនបានដើរ ។ ក្រោយមក ខ្ញុំលួចសួរមេម្នាក់ដែលមានឋានៈក្បែរខ្ញុំដែរនោះថា គេដើររកអ្វី? គេថា ដើរបោសម្អាតខ្មាំង ។ ខ្ញុំសួរថាខ្មាំងនៅណា ប្រាប់មក អញទៅវាយ ។ គេថាដើរបោសសម្អាតខ្មាំងចេញពីក្រុង ។ សួរចុះសួរឡើងគេដើរដេញប្រជាជនឲ្យចេញពីក្រុង ព្រោះខ្លាចខ្មាំងនៅលាក់ខ្លួន ខ្លាចធ្វើរដ្ឋប្រហារវិញ ។ ខ្ញុំថាឆ្កួត ប្រជាជនណាមានអាវុធមកធ្វើរដ្ឋប្រហារ ហើយគេក៏ទៅបាត់ទៅ ។ រួច

ហើយគេឲ្យខ្ញុំទៅវាយរហូតដល់រំដោះ ។

ប៊ុនថន : ពូនៅ៣ឆ្នាំ អត់មានបានដើរទៅណាទេ?

ឆាយ : មិនមានបានទៅណាទេ ។

ប៊ុនថន : ចុះទស្សកិច្ច?

ឆាយ : ទៅបានជិតៗ ដូចជាស្ទឹងជើងឯកបានទៅ ។

ប៊ុនថន : ទៅលេងឬយ៉ាងម៉េច?

ឆាយ : ទៅលេង ។ គំនិតខ្ញុំថា ខ្ញុំចង់ដើរលេងឲ្យដឹងសភាពការណ៍ កាលនោះនៅរោងចក្រកែវ ។ ខ្ញុំចង់ដឹងពីសភាព កាលនោះខ្ញុំនិយាយថាអឺអញទៅរកវាលាសលេង កាលនោះទឹកវាក់ ។ ទៅវាលាសគោះ អានេះទៅជាមួយ ខ្ញុំសុំមេគេទៅ តែតាមពិតទៅដើម្បីស៊ើបការ ។ ទៅអត់មានឃើញអី ក្រោយរោងចក្រកែវ អាបឹងជើងឯកនោះមានមុងចិន ។ កន្លែងនោះដាក់កាំភ្លើងដេសេអាបាញ់យន្តហោះ ។ អត់មានការក៏មកវិញមក ។ យើងដើរនៅជិតៗហ្នឹងអត់មានដើរឆ្ងាយទេ ។

ប៊ុនថន : ពូមានដើរទៅមុខវាំង ឬមាត់ទន្លេ?

ឆាយ : អត់មានបានចូលទេម្តុំនោះ ។

ប៊ុនថន : អត់មានអផ្សុកទេ?

ឆាយ : អផ្សុក ប៉ុន្តែជិនាន់នោះវានៅជាប់កំរែលជំនាន់បីឆ្នា ។ បើនៅសង្គ្រាមថា មេអន្ទុយនៅណាយើងអន្ទុយនោះហើយ ចាំតែទទួលរបាយការណ៍ពីគេ ។ តែបរិវេណយើង យើងដើរបានយើងនៅហ្នឹង តែខទាហរណ៍ពេលមានដូវបំបែកយើងទៅបាន ។ បើយើងជិះកង់ជិះម៉ូតូក្រឡឹងទៅឃើញ អត់មានដើរច្រកល្ហកទៅណា ។ គ្រាន់តែប្រវែងហ្នឹង មុខវាំងអត់បានមកជិតផង ។

ប៊ុនថន : មានទៅលេងឪពុកម្តាយទេកាលមកនៅភ្នំពេញ?

ឆាយ : ខ្ញុំទៅមួយសារនោះ ឪពុកម្តាយខ្ញុំនៅ ។ ដល់ខ្ញុំមកវិញវាបាត់ជ្រៀប ខ្ញុំដែលទទួលដំណឹង ។ ដល់យួនចូលមកវាយដល់នេះហើយ បានខ្ញុំឮដំណឹងថា ម្តាយខ្ញុំគេយកទៅវាយសម្លាប់ចោលដល់ដឹងយើងរត់ទៅមិនកើត ព្រោះអានេះវាយមកដល់ហើយ ។

ប៊ុនថន : ចោះពេលបែកភ្នំពេញនៅជាកន្ទែព?

ឆាយ : ទៅ ប៉ុន្តែអត់បានជួបនឹងម្តាយខ្ញុំទៀត ។ ម្តាយខ្ញុំទៅលេងផ្ទះបងខ្ញុំនៅកោះទីវ ។ ខ្ញុំទៅជួបតែឪពុកខ្ញុំទេ ។ មកវិញមកនៅរោងចក្រកែវវិញហើយ ហើយរហូតមិនដែលបានជួបទេ ។

ប៊ុនថន : ឆ្នាំ៧៧ទៅវាយនៅស្វាយរៀងខាងណាចាត់តាំងឬ?

ឆាយ : ភូមិភាគ ។

ប៊ុនថន : ទៅច្រើនទេ?

ឆាយ : កងទ័ពច្រើនណាស់ ។ ប៉ុនយើងអត់ដឹងថា ទៅមុខសញ្ញាណាទេ ។ ខ្ញុំទៅដល់ស្វាយរៀងមិនទាន់បានវាយស្រួលបួល ពួសូវខ្ទប់ពីមុខខ្ទប់ពីក្រោយ ខ្ញុំក្រវាត់កាំភ្លើងចោល ។

ប៊ុនថន : ពូមានបានវាយទេ?

ឆាយ : ថាឡើងទៅវាយទប់ អាពីមុខបុកមក ។ កម្លាំងយើងវាតិច ក៏ដកថយ ហើយអាពីក្រោយទប់ពីក្រោយទៀត ចង់ងាប់ ។ អញ្ចឹងខ្ញុំក៏បោះកាំភ្លើងចោល ។

ប៊ុនថន : ទៅវាយនៅសមរភូមិណា?

ឆាយ : តាយនីញ ។

ប៊ុនថន : រំដួល ឬរមាសហែក?

ឆាយ : តំបន់ដីស្អុះ គឺជាដីយើងធម្មតា ។ វាដូចជាស៊្វីង ប៉ុន្តែមិនដឹងថាគេហៅភូមិអីទេ ។ ទំហំវាធំដែលមានទទឹងប្រហែលជាង១០ម៉ែត្រ ប៉ុន្តែថ្ងៃមកដីវាឡើងប្រេះក្រហែង ។ ដើងទទេ ដើរលើលេចភ្លីប ប៉ុន្តែបើដាក់ក្តារ ឬឈើ អត់អីទេ ។

ប៊ុនថន : ដីជាន់ទៅផុង?

ឆាយ : អត់ផុងទេ វាគឺជាដីបែងក្រហែង ប៉ុនកុំដើរជើងទទេ ។ បើដាក់ក្តារទ្រាប់អត់អីទេ ។

ប៊ុនថន : បានវាយទេ?

ឆាយ : អត់បានទេ ទៅដល់គេខ្ទប់ពីមុខ ពីក្រោយ ខ្ញុំរត់ ។

ប៊ុនថន : តើពូហែលឆ្លងទឹកទន្លេអ្នកលឿង ហើយចូលរោងចក្រកែវឬ?

ឆាយ : ខ្ញុំហែលហើយ ខ្ញុំនៅជាមួយក្មេីនៅរោងចក្រកែវ សុំវានៅជាមួយ ។

ប៊ុនថន : គាត់ធ្វើអ្វី?

ឆាយ : ធ្វើកម្មករដូចគ្នា ។ ប៉ុនកាលជំនាន់នោះ ដឹងតែគេបញ្ជូនខ្ញុំទៅនោះ ប៉ុនគេអត់ដឹងខ្ញុំរត់មកនៅរោងចក្រកែវទេ ។ ប៉ុននៅស្ទូមិនទាន់បានប៉ុន្មាន គេថាក្បត់លិចក្បត់កើត មិនបានធ្វើអ្វីផង ។ ដល់ពេលយួនចូលមក គេដកទៅនោះតែម្តង ។ រុញទៅទាំងអាក្មេីខ្ញុំនោះទៅព្រែកក្តាម ធ្លាក់ទឹកចង់ងាប់ ចងរស់ ។

ប៊ុនថន : ពូរត់ទៅដល់ម៉ាឡៃឆ្នាំប៉ុន្មាន?

ឆាយ : ខ្ញុំរត់មកដល់នេះពាក់កណ្ដាលឆ្នាំ១៩៧៩ ។ នៅពេលនោះគឺគ្រែមរណៈ រហូតដល់ឆ្នាំ៨០ មានពន្លឺបន្តិចឡើងវិញ ។ ដល់ឆ្នាំ១៩៨១ ខាងលើនោះមានអាវុធវៀងខ្លួន បានធូរធា បន្តិច ។ កាលមុនតំបន់នេះកុំចូល ២០នាក់ងាប់ទាំង២០ មានខ្លា ដំរី ។

ប៊ុនថន : កាលចូលមកដំបូងមានអ្នកនៅទីនេះ ឈ្មោះ តាហុង គ្រប់គ្រង?

ឆាយ : តា ហុង មិនមែនអ្នករស់នៅនេះទេ ។ គាត់រស់នៅភ្នំពេញដូចគ្នា ។

ប៊ុនថន : តើគាត់មកមុនពូ?

ឆាយ : មិនដឹងគាត់មកដល់ពេលណា ប៉ុនយើងមកដល់ គាត់នៅស្រែសាម៉ន ។ គាត់មានបណ្ដាញ ដឹកនាំឲ្យទៅជួបនៅស្រែស្រម៉ន ។ ប៉ុនមិនដឹងប្រវត្តិគាត់នៅឯណា តែដឹងថាគាត់នៅបាត់ ដំបងតាមខ្ញុំដឹង ។

ប៊ុនថន : តើមានផ្លូវធំដូចសព្វថ្ងៃនេះទេ?

ឆាយ : អត់មានផ្លូវទេ ។

ប៊ុនថន : ចុះរត់តាមផ្លូវណា?

ឆាយ : យើងរត់កាត់ព្រៃ ។ ឧទាហរណ៍ថា ខ្ញុំរត់មានមុន មានផ្លូវបន្តិច ។ អ្នកតាមក្រោយមកតាម ផ្លូវនេះទៀតហើយ ។ បេះតែមកបន្តមក កើតជាផ្លូវ ។ កាលនេះផ្លូវធំគេហៅ ផ្លូវ៥០២ នោះមាន ។ នោះផ្លូវខាងថៅកែយ៉ គេអូសឈើ ។ ផ្លូវនោះមកពីខាងកូនដំរីត្រង់ទៅភ្នំ ។

ប៊ុនថន : ចុះផ្លូវវាងមកនេះ?

ឆាយ : អានោះទើបនឹងធ្វើក្រោយ ។ គេធ្វើដំណើរដើរជើង ។ ឧទាហរណ៍ថា កងទ័ពនៅព្រំដែន យើងធ្វើផ្លូវក្រវ៉ាត់ការពារដើរបេះមក ។ អ៊ីចឹងទៅកើតជាផ្លូវឡានចឹងមកបើគេចខ្លាចប៉ះមីន ។

ប៊ុនថន : ដំបូងសុទ្ធតែព្រៃឬ?

ឆាយ : ព្រៃទាំងអស់ ។ តើជឿខ្ញុំទេ ដើមម្ទេស ប៉ុនពាន ។ នៅត្រង់ផ្ទះនេះ ។ អត់មានឃើញពន្លឺ ថ្ងៃទេ ហើយបើទៅដេកនៅក្រោមនោះមួយយប់ឡើងញ័រ ។ ហើយយប់ឡើង និយាយពីភ្លឺ ដូចយើងដាក់អគ្គិសនី គឺវាមានជាតិបារ៉ត ។

ប៊ុនថន : ពូមកដំបូងច្រើននាក់ទេ?

ឆាយ : ច្រើនណាស់ ប៉ុនវានៅតិច ។

ប៊ុនថន : ចុះទៅបូកខាងស្រែស្រម៉ន?

ឆាយ : ឧទាហរណ៍យើងមកដល់នេះប៉ុន្មាន បែកទៅគេនោះប៉ុន្មាន ។ ខាងគេនោះ យើងអត់គិតទេ គិតតែនៅខាងយើង ។ ខ្ញុំសរុបមកដល់ដំបូងបំផុត ខ្ញុំស្មានថា៥០០នាក់ ។ អានេះម៉ាកំណាត់

នៅយើងនេះ អត់និយាយខាងសំពោលូន យើងនិយាយតែស្រុកម៉ាខ្មែ ។ អាហ្នឹងមានកង សន្តិសុខគេមក មានខាងស្រីៗដឹកជញ្ជូនខ្លះ ។ ដល់ក្រោយមក គេដកមកពីជំរំ ជំរំស្រះកែវ បានមនុស្សច្រើនបន្តិច ។

ប៊ុនថន : មកដំបូងនារី និងបុរសនៅជុំគ្នា?

ឆាយ : នៅដូចបងប្អូន ។

ប៊ុនថន : មានគ្រួសារ?

ឆាយ : អត់មានទេ ។ អ្នកមានគ្រួសារ គេហួសទៅខាងអ៊ីដាង ទៅស្រះកែវអស់ហើយ ។ គេចេញទៅបរទេសអស់ ។ កាលមកដំបូងមនុស្សច្រើនដែរ នៅសល់ប្រហែលតែ៥០០នាក់ ។ ខ្លះចេញទៅអាមេរិក ខ្ញុំឡើងឡានទៅនឹងគេដែរ តែនឹកឃើញមិនទៅងាប់ស្រុកគេទេ ។

ប៊ុនថន : ឆ្នាំ៨០ចាប់មានគ្រួសារទេ?

ឆាយ : ចាប់ផ្តើមមានគ្រួសារ ដល់ឆ្នាំ៨១-៨២ ចាប់មានច្រើនហើយ ។

ប៊ុនថន : ចូលមកដល់ដំបូង តើវៀតណាមវាយចូលមកដល់ទេ?

ឆាយ : វៀតណាមចូលមកដល់ដែរ ប៉ុនអត់ហ៊ានទៅអែបព្រំដែនទេ ។

ប៊ុនថន : ពូរៀបការឆ្នាំណា?

ឆាយ : ឆ្នាំ១៩៨១ ។

ប៊ុនថន : រៀបការជាមួយគេ?

ឆាយ : រៀបការចាប់ដៃគ្នា១០គូ ២០គូ ។

ប៊ុនថន : នៅមានទៀត?

ឆាយ : យើងនៅជំនាន់នោះដដែល មិនទាន់ផ្លាស់ប្តូររបបទេ ។ ក្រោយសមាហរណកម្មមក ទើបយើងផ្លាស់ប្តូរ បំភ្លេចចោលរបបនោះ ។

ប៊ុនថន : ពូស្គាល់ពីមុនមក?

ឆាយ : គ្រួសារសព្វថ្ងៃនេះ ខ្ញុំទើបបានក្រោយ ។ នេះរូបថតគ្រួសារចាស់ខ្ញុំ ពាក់អាវក្រហម ។ នេះខ្ញុំទើបនឹងបានក្រោយ ។

ប៊ុនថន : គ្រួសារចាស់ស្លាប់ប្តុយ៉ាងម៉េច?

ឆាយ : ស្លាប់ ។ មិនមែនជំងឺផង ស្រាប់តែអន្តុយៗទៅបណ្តោយ ។

ប៊ុនថន : ស្លាប់ឆ្នាំណា?

ឆាយ : បីឆ្នាំហើយ ។

ប៊ុនថន ៖ គ្រួសារក្រោយពូមកទីនេះតាំងពី...?

ឆាយ ៖ មកដូចគ្នា តាំងពីរត់ដូចគ្នា ។ ប៉ុនដូចថាគ្នាមិនសូវបានទ្រីស្តីទេ មិនសូវចាំ ។

ប៊ុនថន ៖ ឆ្នាំណាដែលវាយខ្លាំងទៅវិញទៅមក?

ឆាយ ៖ កាលនោះចេះតែវាយដេញៗមក ។ មកដល់ព្រៃខ្មែរក្រហមមានអីទៅតតាំងទៀត អស់ហើយ ។ ដូចខ្ញុំនិយាយដូចនៅលើគ្រែមរណៈហើយ ។ គ្រែស្លាប់ហើយ អត់មាននរណារស់ទេ ។ មានកម្លាំងណាទៅវាយ ។ ដល់វាយៗឈប់ ហើយក៏រត់ទៅ អត់មានវាយធំទេ ។ ដល់ក្រោយពី១៩៧៩ ឡើងមកដល់ឆ្នាំ១៩៨០ ចាប់ផ្តើមវាយខ្លាំងបន្តិច ។ ចាប់ផ្តើមវាយទីតាំងនេះបន្តិច នោះបន្តិច ចាប់ផ្តើមធ្វើចលនា ចេះតែពង្រីកខ្លួន ។ ចាប់តាំងពី៨០,៨១, ៨២ និង៨៣, ៨៤, ៨៥ វៀតណាមចូលមកមួយសារទៀត រត់ធ្លាក់ចូលដីថៃ ចូលដីរំអស់ ។ ដល់ឆ្នាំ៨៥ ចាប់ផ្តើមធ្វើសកម្មភាពនៅក្នុង ។ អត់វាយនៅនេះទៀតទេ ។ ៨៥, ៨៦, ៨៧ យួនដកចេញពីតាមភ្នំអស់ ។ យើងធ្វើសកម្មភាពនៅខាងមុខ ដូចថាកាត់សរសៃឈាម អាទឹកក៏មិនបានមក អាអង្ករក៏អត់បានមក ដូចថាទៅស៊ីអី មិនស៊ីដុំថ្ម ។ ដល់ហើយដកចេញអស់ ហើយយើងក៏ចូលមកនៅវិញ ។ យើងបង្កើតបាន ហើយចេះតែវាយដេញទៅរហូតមក ។ ដល់ឆ្នាំ៩០ យើងមិនមានអ៊ុនតាក់មួយសារ ជិនាន់អ៊ុនតាក់ចូលមកផ្សះផ្សាយើងមិនត្រូវគ្នាមួយសារហើយ ។ ដល់មិនដឹងម៉េច មកដល់៩៣នេះ យើងមិនទគ្នាមួយសារទៀត ។ ទគ្នាមកដល់អ៊ុងម៉ុង មកដល់ខ្លាងាប់នេះ ។ វាយគ្នានឹងខ្មែរគ្នាឯង មិនជៀលគ្នាទៅវិញទៅមក ។ ខាងនេះគេថា អាខ្សែខ្ញុំកញ្ឆះយួន ខាងនេះមិនថា អា ប៉ុល ពត ។ ប៉ុន្តែការពិត វាយបណ្តើរ តែល្បិចលូកចាប់ដៃគ្នាបណ្តើរ ។ ដល់ពេលក្រោយមក យើងមិនឲ្យអ៊ុនតាក់ឯណា ។ សម្តេចនាយក លោកមិនស្រែកថា ម៉េចទេ បានជាខាងនេះលោកថា ខ្មែរមិនវាយខ្មែរ ហើយខាងនោះក៏ថាខ្មែរមិនវាយខ្មែរ រួមសាមគ្គីគ្នា ។ ដល់ក្រោយមក មានគេមួយចំនួនគេបដិសេធថា មិនឲ្យទទួលស្គាល់ខ្មែរក្រហមទេ ប៉ុន្តែសម្តេចនាយកថា គាត់អ្នកទទួលខ្មែរក្រហមឲ្យនៅក្នុងច្បាប់ ។ អីចឹងគាត់ទទួលស្គាល់ ដល់ពេលធ្វើសមាហរណកម្ម គាត់មកដល់មុនគេ ។ ចាប់ដៃខ្មែរក្រហមមុនគេ ។ អីចឹងបានជាគាត់ថា តំបន់ណាក៏គាត់អត់ខ្លាចតំបន់ខ្មែរក្រហមក៏គាត់អត់ខ្លាចដែរ នៅម៉ាឡៃក៏គាត់អត់ខ្លាចដែរ ព្រោះគាត់មកមុនគេ ។ ដល់ហើយ ហ៊ុនស៊ីនប៉ិចមកដល់ក្រោយ ។ មួយទៀតលោក សម រង្ស៊ី គាត់បានតែស្រែកទេ ប៉ុន្តែសមិទ្ធិផលបន្តិចអត់មានទេនៅស្រុកម៉ាឡៃនេះ ។ មានតែរបស់សម្តេចនាយក និង

ខាងនរោត្តមរណឫទ្ធិបានសាលាមួយខ្នង ។ ក្រៅពីនោះ សមិទ្ធិផលរបស់សម្តេចនាយកទាំងអស់ គ្រប់កន្លែង ។

ប៊ុនថន : កាលពូនៅហ្នឹង នរណាអ្នកគ្រប់គ្រងកម្លាំងខាងខ្មែរក្រហម?

ឆាយ : កាលយើងនេះមាន ប៉ុល ពត តាម៉ុក តា នួន ជា និង តា សុន សេន ។ ប៉ុន្តែនៅក្នុងសៀវភៅនោះ មានតា ប៉ុល ពត និងតា អៀង សារី ទៀត ។ ប៉ុន្តែការគ្រប់គ្រងតាំងពីដើមមក មានតែ៤នាក់ហ្នឹងអ្នកគ្រប់គ្រង ។ តាម៉ុក ជាមេធំខាងលើ គេហៅស្នងការ ឯតា នួន ជា និង សុន សេន នេះជាបញ្ជាការ ហើយពីរនាក់នោះ គាត់អត់ដឹងរឿងអីទេ ។ ដល់ពេលជាប់ គាត់ទាំងពីរនាក់នោះដែរ ។

ប៊ុនថន : ចុះមេបញ្ជាការផ្ទាល់របស់ពូ?

ឆាយ : មានតានួន ជា និងតាសុន សេន ។ តែតាម៉ុក បានតែស្រែកឆ្ងាយ ហើយតាប៉ុល ពត អត់ដែលឃើញមុខទេ ។

ប៊ុនថន : ប៉ុល ពត អត់ដែលមកនេះទីនេះទេ?

ឆាយ : អត់ដែលទេ ។

ប៊ុនថន : គាត់នៅណា?

ឆាយ : កាលនោះគាត់នៅដងរែក ។

ប៊ុនថន : ចុះតាម៉ុក?

ឆាយ : នៅដងរែកដូចគ្នា ។ ប៉ុននៅនេះមានតែតា នួន ជា និងតា សុន សេន នៅជាប់ និងបញ្ជាចេញមក ។ បញ្ជាមកប៉ះឧត្តមសេនីយ៍ សុខ ភាព ។ ដល់បញ្ជាដល់គាត់ គាត់ពើងទ្រូងព្រោះគាត់ទាក់ទងជាមួយរាជរដ្ឋាភិបាលហើយ បញ្ជាម៉េចក៏គាត់អត់ធ្វើតាម ។ គាត់ទាក់ទងជាមួយតា អ៊ី ឈាន ប៉ៃលិន ។ បើធ្វើសមាហរណកម្មនោះមុន ខាងនោះធ្វើអន្តរាគមន៍មកខាងនេះជួយ ។ ខ្ទប់កណ្តាលមក ខ្ទប់កន្លែងតា សុន សេន កុំឲ្យរើរួច ។ បើខាងនេះធ្វើសមាហរកម្មមុន វាយខាងនេះទៅខ្ទប់គាត់ឲ្យជាប់ ។ ដល់បញ្ជាខ្លាំងៗ ខាងនេះផ្តាច់ខ្លួនសមាហរណកម្ម រាជរដ្ឋាភិបាលបើកដៃ ហើយកងទ័ពធ្លាប់នៅជាមួយគ្នា ។ យើងឡើងទៅភ្នំរូងស្រែកមេក្រូថា បងប្អូនទាំងអស់គ្នាគួរតែទម្លាក់អាវុធ ឈប់ធ្វើសង្គ្រាម បងប្អូនទៅរស់នៅជាមួយប្រពន្ធកូនរបស់បងប្អូន យើងធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល ។ ថាចុះថាឡើង ខាងនេះទម្លាក់អាវុធអស់ យើងទៅប្រុយ ។ ទៅចាប់ដៃគ្នា យើងហីអើតាំងពីនោះរហូត ។

ប៊ុនថន ៖ ខ្ទប់កម្លាំង សុន សេន មិនឲ្យទៅខាងរដ្ឋាភិបាលឬយ៉ាងម៉េច?

ឆាយ ៖ ទេ។ តា សុន សេន ចង់បង្ក្រាបយើង មិនឲ្យទៅខាងរដ្ឋាភិបាលទេ។ ប៉ុន្តែដោយសារយើងដឹងថា បើនៅសង្គ្រាមទៀតវានាំឲ្យវិនាសអន្តរាយ។ អ៊ីចឹងច្របាច់បញ្ចូលគ្នា ដល់ប៉ៃលិនច្របាច់ហើយនៅតែកណ្តាលបន្តិច ដូច្នេះយើងច្របាច់វាឲ្យជាប់។ បានយើងធ្វើសមាហរណកម្មរហូតដល់សំឡូត រហូតដល់កោះកុង និងម៉ាជំនៀវព្រំដែននោះ គឺដឹងពីម៉ាឡៃ និងប៉ៃលិនទៅមុន អ្នកនាំទៅបានជាមានសមាហរណកម្មតៗគ្នារហូត។

ប៊ុនថន ៖ ចុះ សុន សេន គាត់នៅខាងណា?

ឆាយ ៖ គាត់នៅតំបន់៣២។ ខាងសំពៅលូន គាត់នៅផ្ទះគាត់នោះ។

ប៊ុនថន ៖ ចុះនៅទីនោះ តា អៀង សារី គ្រប់គ្រង?

ឆាយ ៖ អត់ទេ។ កាលគាត់មកនៅផ្ទះគាត់នៅនេះ។ គាត់អត់គ្រប់គ្រងអីទេ គាត់មកជាប្រជាជនសាមញ្ញធម្មតា។ កុំអីគាត់អត់មកទេ ប៉ុន្តែយើងអញ្ជើញឲ្យគាត់មកនៅ ព្រោះអតីតពីដើមគាត់នៅជាមួយយើង ដល់ហើយគាត់ទៅក្រៅប្រទេសទៅ។ ដល់ហើយយើងអញ្ជើញគាត់មកវិញ។

ប៊ុនថន ៖ គាត់មកឆ្នាំប៉ុន្មាន?

ឆាយ ៖ ខ្ញុំភ្លេចដែរ មិនដឹងជាឆ្នាំប៉ុន្មានទេ។

ប៊ុនថន ៖ ៩០ជាងឬ?

ឆាយ ៖ កាលសមាហរណកម្មហើយ ៩៧, ៩៨ នេះឯង។ គាត់មកមុនសមាហរណកម្មបន្តិច។ គាត់ដឹងថា យើងរំដើបរំដួលៗចង់សមាហរណកម្មជាមួយរដ្ឋាភិបាល គាត់មកព្រឹប។ គាត់អត់មានទំនាស់អីទេ គាត់បន់ឲ្យតែយើងធ្វើ នឹងអាលគាត់មកដែរ។

ប៊ុនថន ៖ ចុះម៉ាឡៃចូលមុនគេឬ?

ឆាយ ៖ ចូលមុនគេ។ ម៉ាឡៃ និងប៉ៃលិន ចូលមុនគេបំផុត ព្រោះពីរនាក់ហ្នឹងទាក់ទងគ្នាហើយ។ សុខភាព និង អ៊ី ឈាន ទាក់ទងគ្នាជាប់។ គាត់ថា បើខាងប៉ៃធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលហើយ ហើយមក អ៊ីចឹងខាងម៉ាឡៃខាងទៅជួយដើម្បីខ្ទប់គ្នា កុំអ្នកនៅកណ្តាលដែល តា សុន សេន នៅនោះកុំឲ្យមកធ្វើវិទ្ធង្សនាជាមួយមួយ។ អ៊ីចឹងយើងខ្ទប់គាត់ឲ្យជាប់។ ប៉ុន្តែខាង តា អ៊ី ឈាន គាត់ធ្វើសមាហរណកម្មភ្លាម ខាងនេះក៏ធ្វើព្រម យើងទៅជួបគ្នានៅភ្នំព្រឹក។ កន្លែងឃ្លាំងធំតា សុន សេន។

ប៊ុនថន ៖ ចុះ សុន សេន?

ឆាយ ៖ រត់ចេញទៅថៃបាត់ មិនដឹងទៅណាបាត់ៗ អញ្ចឹង តា អ៊ី ឈាន ថា បើយើងធ្វើអីចឹង ហើយ យើងទៅផ្សះផ្សាប្រជាជននៅតាមបណ្តោយព្រំដែនឲ្យចូលជាមួយរដ្ឋាភិបាលៗ យើងទៅមែន រហូតឆ្ងាយទៅដល់កោះកុងៗ ក្រោយគេទៅខាងដងរែក និងអន្លង់វែងៗ

ប៊ុនថន ៖ ចុះក្រោយមក ពូមានដឹងថា សុន សេន ទៅនៅខាងអន្លង់វែងហើយមានទំនាស់ទេ?

ឆាយ ៖ នៅនេះគាត់ដឹងថាមិនសុខ គាត់ថាពួកនេះក្បត់អស់ហើយៗ គេចោទថា ពួកនេះក្បត់បក្ស ចូលទៅចូលជាមួយអាយ៉ងយួនៗ អីចឹងគាត់រត់ទៅខាង ប៉ុល ពត និងតា ម៉ុក ធ្វើអន្តរាគមរៀបចំធ្វើវិទ្ធង្សនា ដើម្បីពង្រឹងពួកនោះដាច់ខាតកុំឲ្យធ្វើសមាហរណម្មជាមួយរដ្ឋាភិបាលៗ ខាងនេះចូលអស់ ដោយសារទ្រាំមិនបានព្រោះកម្លាំងទូទាំងចូលអស់ នៅសល់តែពីរដែលនៅបានៗ ពេលនោះខាងរដ្ឋាភិបាលទៅគំរាម ហើយខាងនេះគំរាមទៀតទៅថា ត្រូវតែធ្វើសមាហរណកម្ម បានជាធ្វើសមាហរណកម្មៗ អត់ពី ប៉ុល ពត គាត់សម្លាប់ទៅ មាននរណាធ្វើអីទៀតៗ ចប់ទៅៗ

ប៊ុនថន ៖ នៅនេះសមាហរណកម្មនៅឆ្នាំណា?

ឆាយ ៖ ៩៧, ៩៨ អាហ្នឹង សម្តេចនាយកគាត់មកៗ យើងរាប់ឲ្យវែងតាំងពីទាក់ទងផ្លូវសម្ងាត់ ៩៦, ៩៧, ៩៨ បានគាត់មកៗ នៅមុនពេលគាត់មក គេប្រកាសស្រុកម៉ាឡៃទៅមិនបានទេ កាលពីជំនាន់ ប៉ុល ពតៗ គាត់ថា អត់អីទេ ទុកឲ្យខ្ញុំទៅៗ គាត់មកអត់មានកងទ័ពអីមកប៉ុន្មានៗ មកចុះពីយន្តហោះ យើងឡានជូនគាត់ដើរមាននរណាធ្វើអីៗ

ប៊ុនថន ៖ កាលនោះខាងណាមកខ្លះ?

ឆាយ ៖ គាត់មកតែគាត់ទេ ប៉ុន្តែមិនដឹងថា គណប្រភូណាមកអមគាត់ ខ្ញុំអត់ស្គាល់ទេៗ ខ្ញុំដឹងថា គាត់ៗ គាត់មកដល់សួរអ្នកស្រុកម៉ាឡៃទៀតៗ គាត់សួរខ្ញុំផ្ទាល់តែម្តងថា តាំងពីឆ្នាំ១៩៧៩ ដែលទៅលេងស្រុកទេ? ខ្ញុំថា តាំងពីឆ្នាំ១៩៧៩ មិនដែលបានទៅលេងស្រុកទេៗ អញ្ចឹងចង់ទៅទេ? ខ្ញុំថាចង់ៗ អីចឹងមិនអីទេ គាត់យន្តហោះមកយកៗ គាត់ឲ្យហោះមកយកមែន គាត់ទៅដុតបានមួយថ្ងៃ ស្អែកឡើងអាកន្ទុមរុយមកពីរៗ មកចុះនៅផ្សារយើងហ្នឹងៗ

ប៊ុនថន ៖ ផ្សារម៉ាឡៃ?

ឆាយ ៖ បាទ កាលនោះមិនទាន់មានផ្ទះថ្មធំៗទេៗ យន្តហោះមកពីរ ដល់ហើយគាត់កត់ឈ្មោះខ្ញុំឲ្យទៅលេងស្រុកៗ ដល់ពេលយន្តហោះមកដល់ អាអ្នកមានឈ្មោះអត់បានទៅ បានទៅអាអ្នកស្គាល់តែកុងយន្តហោះនោះវិញៗ ខ្សែស្រឡាយនាំគ្នាទៅអស់រលីងៗ

ប៊ុនថន ៖ មានសម្តេច សីហនុ គាត់មកទេ? និង ញឹក ប៊ុនឆៃ?

ឆាយ ៖ កាលនោះមកតែសម្តេចនាយកទេ ។

ប៊ុនថន ៖ ចុះកន្លែងសារគាំង?

ឆាយ ៖ នោះកន្លែងសម្តេច អតីតកន្លែងសម្តេចចាស់ ។ កន្លែងនោះបារមីខ្ពស់គ្រាន់បើដែរ យើងគិតមើលដំបូលស្បូវសោះ ដុតទៅឆេះតែស្បូវ បង្គន់អត់ឆេះ ។ ហើយគ្រាប់ផ្លោងធ្លាក់ ឃើញតែផ្ទុះ ប៉ុន្តែអត់មានបាក់អី ។ អ៊ីចឹងបានធ្វើកន្លែងបារមីសម្តេចតានោះ ដាក់ព្រះពុទ្ធរូបមួយអង្គត្រង់នោះហើយ ។

ប៊ុនថន ៖ សម្តេចគង់នៅឆ្នាំប៉ុន្មាន?

ឆាយ ៖ សម្តេចមកនោះឆ្នាំ៨០,៨១ ឬ៨៣ ។ កាលនោះខ្ញុំភ្លេចដែរ ខ្ញុំវាយនៅខាងផាប់ ។ នៅនេះព្រោះសារគាំងនៅនេះ គ្រប់ប្រទេសមកនៅនេះ ។

ប៊ុនថន ៖ ចុះកម្លាំងខ្មែរក្រហមទទួលប៉ុយ៉ាងម៉េច?

ឆាយ ៖ ខ្មែរក្រហមទទួលទាំងអស់ មកដល់អ្នកដែលការពារគេឲ្យនៅចម្ងាយ៥០០ម៉ែត្រអ៊ីចឹង គឺសុទ្ធតែកងការពារទាំងអស់ ។ ខៀវពេញព្រៃ ។ ចូលអត់បានទេ ។ ចូលបានតែគណៈប្រតិភូចុះឡានពីដីថៃមក ។ នាំចូលមក មានកងការពារគេមក ។

ប៊ុនថន ៖ កាលនោះមាន ប៉ុល ពត នៅទេ?

ឆាយ ៖ អត់នៅទេ ។ ប៉ុល ពត អត់នៅនេះទេ ។ នៅតែតា អៀង សារី ទេ ។

ប៊ុនថន ៖ ចុះ នួន ជា?

ឆាយ ៖ នួន ជា នៅខាងត្បូង នៅសំពៅលូន ។

ប៊ុនថន ៖ ខ្ញុំចង់សួរពីប្រវត្តិម៉ាឡៃ តើម៉ាឡៃដំបូង មិនមែនជាស្រុកទេ?

ឆាយ ៖ មិនមែនទេ ។ តំបន់ព្រៃភ្នំសុទ្ធអត់មានភូមិឃុំទេ ។

ប៊ុនថន ៖ ចុះម៉ាហ្នឹងនៅក្នុងអី?

ឆាយ ៖ លោតសទ្ទឹងពីកើតមកវិញ ពីនិមិត្ត ពីកូប ដងអារញ្ញមកវិញ ។ ពីទំបន់កាច់មកវិញ យើងមានហើយ ។ អ៊ីចឹងបើនិយាយពីប្រវត្តិ វាឋិតនៅក្នុងភូមិទំបន់កាច់នោះ ប៉ុនចេញពីមកវាជាព្រៃគឺនរហូត ។ អត់មានផ្ទះសម្បែងទេ មានតែផ្លូវស្រកែយ៉ទេ ដែលមក ។

ប៊ុនថន ៖ វាចូលទៅកន្លែងណា?

ឆាយ ៖ ចូលទៅស្រុកអូរជ្រៅទាំងអស់ ព្រោះមួយកំណាត់ពីស្វាយស៊ីផុនមកលិច ចូលក្នុងស្រុកអូរជ្រៅ ។ ហើយមួយកំណាត់ត្រឹមដងស្ទឹងទៅកើតស្វាយស៊ីសុផុន ។ ប៉ុន្តែក្រោយសមាហរណកម្មយើងកាត់ខេត្តពីបាត់ដំបងឲ្យចូលបន្ទាយមានជ័យ អញ្ចឹងកាត់ពីអូរជ្រៅចូលស្រុកម៉ាឡៃ ។

ស្រុកម៉ាឡៃនេះ យើងមកដល់ដំបូងអត់ទាន់ហៅស្រុកម៉ាឡៃទេ។ មកដល់ហ្នឹង មានថ្ងៃមួយមកនៅហ្នឹង កាលហ្នឹងយើងអត់ដឹងថា ភ្នំអីៗទេ។ យើងអត់ស្គាល់ទេ។ មានថ្ងៃមួយថា នៅកន្លែងយើងនេះ មានថ្ងៃមួយគ្រួសារ មានកូនស្រីពីរនាក់។ គាត់ធ្វើដីនៅភ្នំហ្នឹង ធ្វើចំការនៅភ្នំ។ ដល់តែធ្វើៗរាប់ឆ្នាំអត់ឃើញចេញទៅវិញ។ បាត់ទាំងកូនប្រពន្ធទាំងអស់។ ហើយគេសួរថា ឈ្មោះអី? ឈ្មោះគាត់ តាពេជ្រ យាយសំ។ នៅឯកើត ជាប់ខ្វាងរាប់ទៅខាងត្បូង។ ក្រោយមកទៀត បានគេហៅកន្លែងដែលតាពេជ្រ និងយាយសំ គេឧបត្តិកអាភ្នំតូចនេះថា ភ្នំយាយឡៃ។ យាយ ឡៃ នេះគាត់ទៅកាប់ចំការក្រោយតាពេជ្រ យាយសំទេ។ យាយ ឡៃ នេះមានចង្អូរទឹកមួយចេញពីភ្នំនោះមក។ គាត់ធ្វើនៅជើងភ្នំនោះ។ ដល់ពេលធ្វើយូរៗ គាត់អត់មានកូនមានចៅ គាត់ក៏ស្លាប់នៅហ្នឹងទៅ។ គេឃើញ ក៏ជាប់ជាភ្នំយាយឡៃ ហ្នឹងទៅ។ ឯនៅកើតភ្នំដូនសំនោះ តាពេជ្រក៏បាត់ទាំងរូបគាត់និងកូនចៅទាំងអស់ បានគេឧបត្តិកថា ភ្នំយាយសំ។ តែក្រោយភ្នំយាយសំនោះ យើងឃើញហេតុភេទជាក់ស្តែង។ មានអ្នកនៅរស់ជាមួយខ្ញុំ ជឿទេថា ខ្ទបខ្នុរប៉ុនកំភួនដៃ ហើយស្វាយកែវយើងនេះផ្លែប៉ុននេះ។ ខ្នុរមួយលីម្នាក់ឯងអត់រួចទេ ហើយឈូកប៉ុនចានកំប៉ែតដែលយើងហូបបាយធំជាងគេ។ គ្រាប់ប៉ុនៗមេដៃ។ ហើយបេះកាច់មកមើលទៀត យកមកចែកគ្នាហូប។ ផ្លែគ្រៀបពេញដើមទាំងអស់ ហើយមានអាងទឹកទាំងអស់។ ហើយបើមិនបានកាប់ចំណាំដូចថា ស្រះទឹកយើងកាច់មែកឈើព័ទ្ធជុំវិញ ដូចថាកាប់ដើមខ្នុរហូរជ័រ កាប់ដើមស្វាយ ដឹងគ្រប់ដើមទាំងអស់។ ស្អែកឡើងយើងនាំមកបេះ មិនមែនម្នាក់ពីរនាក់បេះអស់ទេ។ ទៅប្រហែលមួយកងតូច៣០នាក់ដែរ។ សុទ្ធតែបាយ សុទ្ធតែការ៉ុងទៅ។ ទៅដល់ រកអត់ឃើញ។ តែឃើញស្នាមកាប់ តែអាដើមខ្នុរ គឺដើមគុយ ហើយអាស្វាយនោះ គឺដើមក្របៅ ហើយក្នុងស្រះឈូកនោះសុទ្ធតែថ្ម និងដើមឈើ។ នៅតែឆ្ងល់ ព្រោះយើងយកមកហូបទាំងអស់គ្នា ហើយទុកបន្ទុំទៀត។ គ្នាបួននាក់ហូបមួយចំហៀងអត់អស់ទេ។ អង្គុយហូបនៅភ្នំ ហើយយកមកផ្ទះទៀត។

ប៊ុនថន : ឥឡូវមានផ្លូវទៅភ្នំយាយសំទេ?

ឆាយ : អាផ្លូវគេចូល ប៉ុនឡើងភ្នំឬមិនឡើងខ្ញុំអត់ដឹងទេ។ ប៉ុនដើមបេងនៅភ្នំនោះដឹងជាកាប់ឬនៅទេ គ្រាន់តែមែកវាធំជាងពាងទៅទៀត។

ប៊ុនថន : យើងអាចទៅដល់ទេ?

ឆាយ ៖ ផ្លូវមាន តែទៅអត់ដល់ទេ ។ ចាំមើលប្រាំងនេះពួកចិនវាធ្វើផ្លូវ នៅកែងខ្វាងរាប់ ជិតប៉ុស្តិ៍យាម ។ ប៉ុនភ្នំមានពីរ ភ្នំខាងកើតមួយ ភ្នំខាងលិចមួយ ។ ភ្នំខាងកើតទេ ដែលគាត់នៅ ។ យើងមើលពីស្ពាយមកឃើញធំជាងគេ ។ បើទៅឥឡូវខ្វាចរកមិនឃើញ ។ ថ្មដាប៉ុននេះ រាងមូលរាងទ្រវែង ហើយជំរៅប្រហែលពីតឹក អត់មានរន្ធទេ ។ តែយើងទៅបាចអត់រឹងទេ ។ ខ្ញុំចង់ឈ្នះ ខ្ញុំយកត្រឡោកដួងបាច អន្លុយបាចម៉ាហត់អត់រឹង ។ កន្លែងគាត់នោះមានថ្មដាពីរ ម៉ែត្របួនជ្រុង ខ្មៅរលោង ។

ប៊ុនថន ៖ នៅឬទេ?

ឆាយ ៖ មិនដឹង ។

ប៊ុនថន ៖ ពូដែលទៅទៀតទេ?

ឆាយ ៖ កាលនៅទ័ពខ្ញុំខស្បារឡើងចុះ ។

ប៊ុនថន ៖ ឆ្ងាយទេពីផ្សារនេះទៅ?

ឆាយ ៖ ទៅដល់ខ្វាងរាប់ហើយ បានចាក់ទៅត្បូង ។

ប៊ុនថន ៖ ផ្លូវនេះមានមីនទេ?

ឆាយ ៖ គេដោះអស់ហើយ ព្រោះចិនទៅជីកដីនៅភ្នំយាយសំមកចាក់នៅហ្នឹង ។

ប៊ុនថន ៖ គ្រាប់មីនកើតនៅឆ្នាំ?

ឆាយ ៖ ៧៩មិនមានទេ ។ ឆ្នាំ៨០, ៨១ ចាប់មាន ។ អ្នកដាក់ហ្នឹងគ្រោះថ្នាក់តែខ្លួនឯង ។

ប៊ុនថន ៖ នរណាដាក់?

ឆាយ ៖ ខាងយួនក៏ដាក់ ខាងណោះក៏ដាក់ដែរ ។ ប៉ុន្តែខាងយួនមិនសូវដាក់ដូចខាងនេះទេ ។ ពេលគ្រោះថ្នាក់ៗខ្លួនឯង ។ ឧទាហរណ៍ថា យើងដាក់មួយខ្សែហើយ យើងទៅបាត់ ។ អាអ្នកនៅក្រោយអត់ដឹង មកដាក់មួយខ្សែទៀត ដើរទៅដើរជាន់តែរបស់ឯង ។ បើថារឿងវាយគ្នាអ្នកនៅព្រៃកម្រគ្រោះថ្នាក់ណាស់ ។ វាយ៨-១០ដង ដូនអីឃើញរបួសមួយ ។ ស្គាល់ព្រៃអស់ហើយ មិនដែលមានរបួសទេ វាត្រូវតែមីនខ្លួនឯង ។

ប៊ុនថន ៖ ពូថាក្រោយមកបានហូបគ្រប់គ្រាន់នោះ តើបានមកពីខាងណាវិញ?

ឆាយ ៖ មិនជាខាងណាទាក់ទង ប៉ុនសំខាន់មកឧបករណ៍ប្រើប្រាស់ អាវុធ ខោអាវ នំ ម្ហូប អង្ករនោះគឺរបស់ចិន ។ តាំងពីមុន ពីអង្គ្រឹងរបស់ចិនទាំងអស់ ។ ហើយអង្ករនោះអាចមកពីចិនខ្លះនិងប្រទេសផ្សេងខ្លះខ្ញុំមិនដឹងដែរ ។

ប៊ុនថន ៖ បោះកងទ័ពមានបង្ករបង្កើនផលទេ?

ឆាយ ៖ អត់មានទេ។ ពេលមកដល់ក្រោយបានកន្លះខែ ទៅមួយខែ វុញទៅមុខទៀត។ អត់មានបានសម្រាកនៅផ្ទះទេ។

ប៊ុនថន ៖ ចុះពួកគាត់ទៅនៅណាក្នុងទឹកដីថៃ?

ឆាយ ៖ គេបង្កើតជំរំមួយហៅជំ៨៥ ប៉ុននៅក្នុងទឹកដីថៃ។ ដល់ហើយយើងបញ្ចេញកម្លាំងទៅវាយ។ ពេលចង់ឡើងទៅវាយ ដឹកឡានមកដល់ព្រំដែន នាំគ្នារុលទៅក្នុង។ ដល់ហើយនាំគ្នាធ្វើសកម្មភាពនៅក្នុងបាន៦-៧ខែ នាំគ្នាមកវិញ តេប្រាប់គេឲ្យយកឡានមកចាំយក។ ដូរកម្លាំងគ្នាទៅមក។

ប៊ុនថន ៖ តើជីវភាពរបស់ប្រជាជនប្លែកយ៉ាងម៉េចក្រោយពីធ្វើសមាហរណកម្ម?

ឆាយ ៖ ខ្ញុំអរគុណច្រើនណាស់ដែលបានសួរពីចំណុចនេះ។ ក្រោយពីសមាហរណកម្មមក ប្រជាជនមានទឹកចិត្តរីករាយសប្បាយ ដោយសារគាត់មានជីវភាពធូរធាដោយមូលហេតុ គាត់បង្ករបង្កើនផលបាន។ គាត់មានដីសម្បូរមាន ដែលយើងកាប់បានប៉ុន្មាន រត់អត់មានយកពន្ធដារនិងជាស៊ីទេ គឺបើកសិទ្ធិឲ្យយើងធ្វើចំការដោយខ្លួនឯង។ អ្នកណាធ្វើបានប៉ុន្មាន យកប៉ុណ្ណោះទៅ។ អ្នកខំច្រើនបានច្រើន ខំតិចបានតិច តាមកម្លាំងខ្លួនឯង។ ប្រជាជនប្រឹងដោយខ្លួនគាត់ អត់មានខុះខាត។ មានខុះខាតដែរ ចំពោះអ្នកដែលមានជំងឺជំកាត់ មិនបានទៅចាប់ដីនឹងគេ។ នោះវាខុះខាតដែរ តែចំពោះអ្នកដែលមានកម្លាំងទៅចាប់ដីបានអត់មានខុះខាតទេ។ ប្រជាជនរីករាយដោយសារមាគ៌ារបស់សម្តេច។

ប៊ុនថន ៖ មានអ្នកអត់ច្រើនទេ?

ឆាយ ៖ មាន១០០ អត់តែ១០ប៉ុណ្ណោះ ព្រោះកាលមកដល់ដំបូង ចាប់ដីយកវៀងខ្លួន តែអ្នកនោះមកដល់ឈឺទៅដេកពេទ្យ។ ពេលមកដល់គេចាប់យកអស់ មិនមែនថាចាប់បានហើយយកទៅលក់ដូរអីទេ។ អានេះចាប់យកបានដោយវៀងខ្លួន អាខ្លះបាន៣, ៤, ៥ហិកតា អ្នកខ្លះបាន១០០ក៏មានដែរ។

ប៊ុនថន ៖ ចុះអ្នកអត់មានគោលការណ៍ដោះស្រាយទេ?

ឆាយ ៖ រាជរដ្ឋាភិបាលដោះស្រាយ។ ឥឡូវខ្ញុំពូសួរមួយទៀតដីនីតិសម្បទា ដីអតីតយុទ្ធជននៅកន្លែងផ្សេង ប៉ុន្តែបងប្អូនមួយចំនួនគ្នាអត់។ រាជរដ្ឋាភិបាលដោះស្រាយដែរ តែអ្នកទៅនោះ វាមិនទៅ។ អីចឹងបានជាខ្ញុំពិបាកនិយាយដែរ តែមិនដឹងជានិយាយយ៉ាងម៉េច។ ប៉ុន្តែខ្ញុំនៅអន់ចិត្តមួយដែរ ដូចជាកាកបាទក្រហម ឬអង្គការផ្សេងៗដែលចុះមកសម្ភាសបងប្អូន ឬអ្នកក្រីក្រ មូលហេតុចុះមកសម្ភាសបងប្អូននៅម៉ាឡៃហើយ មូលហេតុអ្វីបានជាគ្មានអ្នកក្រីក្រ។

ជូនកាលគាត់មកសម្អាសដល់ខ្ទាំងរបស់ហើយទៅវិញ ។ គាត់មកគាត់ចូលផ្សារ គាត់បាយរួច ហើយគាត់សង្កេតមើល បានគាត់ទៅក្បាលស្ពាន ហើយអាផ្ទះនៅអមក្បាលស្ពាននោះគឺផ្ទះ ធំ ។ ហើយបានគាត់ទៅសាលាស្រុក គាត់មើលឃើញអាហ្នឹងអស់ បានជាគាត់ថា អ្នកនៅ ម៉ាខ្មែរមានណាស់ ។ ប៉ុន្តែគាត់អត់បានចុះទៅចំកាត់មាត់ញ៉ក មានតែតាមដងផ្លូវនេះ ។ អា ផ្ទះនៅខាងក្នុងៗអត់មកមើល ។ ខ្ញុំអន់ចិត្តអត់ចុះមកធ្វើដល់គោលដៅច្បាស់លាស់ បើដល់ ដូចអ៊ីចឹង ដូចលោកគ្រូចុះជួបខ្ញុំផ្ទាល់អ៊ីចឹង ។ បានន័យថា អ្នកហ្នឹងហើយដែលចុះជាប់ស្និតតែ ម្តង ។ ឃើញមូលដ្ឋានអីហ្នឹងយ៉ាងម៉េច ដាក់ស្តែង ។ នោះអត់ទេ ប្រយោលៗប្រុច អាង ថាគេមិនមកមើលផង ។ អញធ្វើឲ្យគ្រប់ថ្ងៃ ទៅវិញទៅ ។ ខ្ញុំអត់និយាយទេ មិនដឹងថា និយាយទៅនរណា ។

ប៊ុនថន ៖ ឥឡូវពូមានកូនប៉ុន្មាននាក់?

ឆាយ ៖ មានកូនបី ប្រុសពីរ ស្រីមួយ ។

ប៊ុនថន ៖ នៅរៀនទេ?

ឆាយ ៖ អត់ទេ មីពៅនេះឈប់រៀនហើយ ។ នេះកូនរបស់វា នេះប្តីវា ។

ប៊ុនថន ៖ មានគ្រួសារទាំងអស់?

ឆាយ ៖ នៅមួយ ។ នៅអាកណ្តាល ។

ប៊ុនថន ៖ ខ្ញុំអស់អីសួរពូហើយ ។ អរគុណពូច្រើន ។

**-ចប់-**